ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការមេ
# អភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប
# ឆ្នាំ ២០២៣-២០៣៥










សម្រេចដោយរាជរដ្ឋាភិបាល ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២៣

## អារម្ភកថា

មរតកនៃ**"នយោបាយឈ្នះ-ឈ្នះ"** បានអនុញ្ញាតឱ្យប្រទេសកម្ពុជាសម្រេចបាននូវការអភិវឌ្ឍលើគ្រប់វិស័យ ក្រោមម្លប់នៃសុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយ និងសុវត្ថិភាពសង្គម ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍជាតិ និងលើកស្ទួយកិត្យានុភាពជាតិទាំងនៅក្នុងតំបន់និងនៅលើពិភព-លោក។ ក្នុងរយៈពេលប្រមាណ២ទសវត្សរ៍ចុងក្រោយនេះ ជាមួយនិងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា ដោយយកប្រជាជនជាធំ សេដ្ឋកិច្ចនៃប្រទេសកម្ពុជាបានរីកលូតលាស់យ៉ាងលឿន ក្នុងអត្រាប្រមាណជាមធ្យម៧%ក្នុងមួយឆ្នាំ ដែលនឹងប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងបានរំដោះប្រជាជនជាច្រើនលាននាក់ពីភាពក្រីក្រ។

ក្នុងដំណើរនៃការអភិវឌ្ឍយ៉ាងលឿននេះ វិស័យទេសចរណ៍គឺជាក្បាលម៉ាស៊ីនជំរុញកំណើនសេដ្ឋកិច្ចយ៉ាងសំខាន់ តាមរយៈការចូលរួមទាក់ទាញការវិនិយោគទាំងក្នុងស្រុកនិងការវិនិយោគផ្ទាល់ពីបរទេស និងជាប្រភពការងារនិងប្រភពចំណូលសម្រាប់លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ ជាក់ស្តែង នៅឆ្នាំ២០១៩ មុនការមកដល់នៃវិបត្តិនៃជំងឺកូវីដ-១៩ វិស័យទេសចរណ៍បានរួមចំណែកប្រមាណ១២,១% នៃផលិតផលក្នុងស្រុកសរុប និងបានផ្តល់ការងារផ្ទាល់ដល់ប្រជាជនប្រមាណ៦៣ម៉ឺននាក់។ កត្តាទាំងនេះបាននាំឱ្យរាជរដ្ឋាភិបាលចាត់ទុកវិស័យទេសចរណ៍ ជាវិស័យអាទិភាពមួយដែលនឹងបន្តដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជាក្នុងរយៈពេលវែងទៅមុខទៀត។

វិបត្តិនៃជំងឺកូវីដ-១៩បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ទូទាំងសកលលោក ប៉ុន្តែស្របនឹងគ្នានេះដែរ វិបត្តិនេះបានបង្កើតជាកាលានុវត្តភាពថ្មីសម្រាប់វិស័យទេសចរណ៍ តាមរយៈការកើនឡើងនៃនិន្នាការមួយចំនួន ដូចជាទេសចរណ៍បែបធម្មជាតិ ទេសចរណ៍វប្បធម៌ និងទេសចរណ៍សហគមន៍ជាដើម។ ដើម្បីទាញយកប្រយោជន៍ពីកាលានុវត្តភាពថ្មីៗទាំងនេះ និងដោយផ្អែកលើសក្តានុពលនៃធនធានធម្មជាតិនិងប្រវត្តិសាស្ត្ររបស់ខេត្តកែប រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែបឆ្នាំ២០២៣-២០៣៥"** សំដៅអភិវឌ្ឍខេត្តកែបឱ្យក្លាយជាគោលដៅទេសចរណ៍សំខាន់មួយសម្រាប់ជាប្រយោជន៍ដល់ខេត្តកែបទាំងមូល ប្រជាជនក្នុងមូលដ្ឋាន និងសម្រាប់លើកមុខលើកមាត់វិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។ ដើម្បីសម្រេចកិច្ចការនេះ ផែនការមេនេះបានកំណត់ចក្ខុវិស័យប្រែក្លាយខេត្តកែបជា **"គោលដៅទេសចរណ៍ធម្មជាតិនិងសមុទ្រសម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់"** ប្រកបដោយសុវត្ថិភាព ភាពទាក់ទាញ និងឧត្តមភាពប្រកួតប្រជែងខ្ពស់លើឆាកអន្តរជាតិ ដោយឈរលើទស្សនាទាននៃការអភិវឌ្ឍទេសចរណ៍ប្រកប ដោយ**គុណភាព សុវត្ថិភាព និរន្តរភាពនៃការគ្រប់គ្រងសង្គម បរិស្ថាន និងធនធានធម្មជាតិបែបវៃឆ្លាត ដោយមានការចូលរួមគិត រួមធ្វើ និងរួមទទួលខុសត្រូវពីគ្រប់ភាគីពាក់ព័ន្ធក្នុងភាពជាដៃគូលើវាសនាតែមួយ។**

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ដល់ឯកឧត្តមបណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ថ្នាក់ដឹកនាំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សារៀបចំផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តកែប និងមន្ត្រីពាក់ព័ន្ធនានា ដែលបានរៀបចំផែនការមេនេះប្រកបដោយភាពជោគជ័យនិងគុណភាពខ្ពស់។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំស្នើឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសក្រសួង ស្ថាប័នសាធារណៈ សហការគ្នាយ៉ាងមុតមាំក្នុងការអនុវត្ត **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥"** ដើម្បីរួមចំណែកក្នុងដំណើរការនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងប្រទេសជាតិទាំងមូល។

ថ្ងៃសុក្រ ១២ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥

## មាតិកា


**១- សេចក្ដីផ្ដើម** ........................................ ១

**១.១- សាវតារ និងស្ថានភាពនៃវិស័យទេសចរណ៍ខេត្តកែប** ........................................ ២

**១.២- ការសិក្សានិងវិភាគទីផ្សារទេសចរណ៍ខេត្តកែប** ........................................ ៤

**១.៣- សក្ដានុពលនៃវិស័យទេសចរណ៍ខេត្តកែប** ........................................ ៥

**១.៤- ស្ថានភាពនៃវិស័យគាំទ្រពាក់ព័ន្ធនឹងវិស័យទេសចរណ៍ខេត្តកែប** ........................................ ៦

**១.៥- ការវិភាគលើស្ថានភាពទេសចរណ៍ខេត្តកែបបច្ចុប្បន្ន (ឆ្នាំ២០២២)** ........................................ ១០

**២- ចក្ខុវិស័យ គោលបំណង និងគោលដៅ** ........................................ ១១

**២.១- ចក្ខុវិស័យ** ........................................ ១១

**២.២- គោលបំណង** ........................................ ១១

**២.៣- គោលដៅ** ........................................ ១១

**៣- ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........................................ ១២

**៣.១- យុទ្ធសាស្ត្រអភិវឌ្ឍន៍ប៉ូលទេសចរណ៍ខេត្តកែប** ........................................ ១២

៣.១.១- ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់ទីក្រុងធម្មជាតិកែបជា "ទីក្រុងធម្មជាតិក្នុងឧទ្យានប្រណិតកម្រិតពិភពលោក" ........................................ ១៣

៣.១.២- ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់អង្កោលជា "តំបន់ទេសចរណ៍ឆ្នេរសមុទ្រធម្មជាតិបែបទំនើប" ... ១៥

៣.១.៣- ការអភិវឌ្ឍប៉ូលទេសចរណ៍ធម្មជាតិតំបន់ភ្នំវល្លិ៍ជា "តំបន់កសិទេសចរណ៍និងទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ" ........................................ ១៧

៣.១.៤- ការអភិវឌ្ឍប៉ូលទេសចរណ៍សមុទ្រនិងតំបន់ប្រជុំកោះជា "តំបន់ទេសចរណ៍សមុទ្រកោះប្រណិត" ១៨

៣.១.៥- យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍតំបន់ប៉ូលទេសចរណ៍ ........................................ ១៨

៣.១.៦- ការអភិវឌ្ឍផលិតផលនិងព្រឹត្តិការណ៍ទេសចរណ៍ផ្សេងៗក្នុងខេត្តកែប ........................................ ១៩

៣.១.៧- ការអភិវឌ្ឍខេត្តកែប-កំពតជាគោលដៅទេសចរណ៍រួម ........................................ ២០

**៣.២- យុទ្ធសាស្ត្រលើកកម្ពស់ការវិនិយោគ អភិវឌ្ឍធនធានមនុស្ស និងផ្សព្វផ្សាយទីផ្សារ** ........ ២០

៣.២.១- ការលើកកម្ពស់វិនិយោគនិងអភិវឌ្ឍធនធានមនុស្ស......២០
៣.២.២- យុទ្ធសាស្ត្រទីផ្សារនិងផ្សព្វផ្សាយ......២១
៣.៣- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ខេត្តកែប......២២
៣.៣.១- យុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍន៍អន្តរវិស័យគាំទ្រ......២៣
៣.៣.២- យុទ្ធសាស្ត្រពង្រឹងខ្សែច្រវាក់ផលិតកម្មក្នុងវិស័យទេសចរណ៍ខេត្តកែប......២៧
៤- យន្តការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តផែនការមេ......២៧
៤.១. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ......២៧
៤.២- ប្រភពហិរញ្ញប្បទានគាំទ្រដល់ការអនុវត្តផែនការមេ......៣០
៥- ការគ្រប់គ្រងហានិភ័យ......៣១
៦- សេចក្តីសន្និដ្ឋាន......៣២
ឧបសម្ព័ន្ធទី១ តារាងផែនការសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ និងវិស័យនានាគាំទ្រវិស័យ ទេសចរណ៍ក្នុងខេត្តកែប ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០៣៥......៦៤
ឧបសម្ព័ន្ធទី២ បញ្ជីឈ្មោះឯកសារអត្តភាពសាធារណៈ......៦៤
ឧបសម្ព័ន្ធទី៣ បញ្ជីឈ្មោះឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធ......៦៦
ឧបសម្ព័ន្ធទី៤ បញ្ជីឈ្មោះតារាង......៦៨
ឧបសម្ព័ន្ធទី៥ បញ្ជីឈ្មោះរូបភាព......៧១
ឧបសម្ព័ន្ធទី៦ បញ្ជីឈ្មោះក្រាប......៧៨

# ខ្លឹមសារសង្ខេប

ខេត្តកែបគឺជាខេត្តក្នុងតំបន់ឆ្នេរ ដែលមានលក្ខខណ្ឌអំណោយផលនិងសក្តានុពលពីធម្មជាតិ សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេស ទេសចរណ៍ធម្មជាតិ និងទេសចរណ៍វប្បធម៌ជាដើម ដោយសារធនធានធម្មជាតិដ៏សម្បូរបែបនិងធនធានវប្បធម៌មួយចំនួនដែលបានបន្សល់ទុកពីមុនមក។ ផ្អែកទៅលើសក្តានុពលទាំងនេះនិងស្របតាមនិន្នាការសកលថ្មីៗ ដែលនាំឱ្យមានការកើនឡើងនៃចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរទូទៅលើគោលដៅធម្មជាតិ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥"** ត្រូវបានរៀបចំឡើង ដើម្បីទាញយកប្រយោជន៍ជាអតិបរមាពីសក្តានុពលទាំងនេះសម្រាប់ធ្វើការអភិវឌ្ឍវិស័យទេសចរណ៍ ឱ្យក្លាយជាគោលដៅទេសចរណ៍មួយប្រកបដោយគុណភាពនិងភាពប្រកួតប្រជែងខ្ពស់ និងជាពិសេសចូលរួមលើកកម្ពស់ជីវភាពរបស់ប្រជាជនក្នុងខេត្តកែប។

ក្នុងស្មារតីនេះ ផែនការមេនេះបានកំណត់ចក្ខុវិស័យប្រែក្លាយខេត្តកែបទៅជា **"គោលដៅទេសចរណ៍ធម្មជាតិនិងសមុទ្រសម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់"**។ ការអនុវត្តផែនការមេនេះ នឹងត្រូវប្រព្រឹត្តទៅដោយប្រកាន់ខ្ជាប់នូវកិច្ចគាំពារបរិស្ថានធម្មជាតិ ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានជីវចម្រុះ ដោយឈរលើទស្សនាទាន **"ការអភិរក្សគាំទ្រដល់កិច្ចអភិវឌ្ឍ និងការអភិវឌ្ឍគាំទ្រដល់កិច្ចអភិរក្ស"** និងទស្សនាទាននៃ **"ការអភិវឌ្ឍទីក្រុងក្នុងឧទ្យានជាតិ"**។ ដើម្បីសម្រេចចក្ខុវិស័យខាងលើ ផែនការមេនេះបានកំណត់យុទ្ធសាស្ត្រសំខាន់ៗចំនួន៣ រួមមាន÷

**ទី១- យុទ្ធសាស្ត្រអភិវឌ្ឍប៉ូលទេសចរណ៍ខេត្តកែប:** សំដៅប្រែក្លាយខេត្តកែបជាប៉ូលទេសចរណ៍ចម្បងមួយតាមរយៈការអភិវឌ្ឍប៉ូលទេសចរណ៍ចំនួន៤សំខាន់ៗ គឺ: ទី១)ប៉ូលទេសចរណ៍តំបន់ក្រុងកែបចាស់ជា"ទីក្រុងធម្មជាតិក្នុងឧទ្យានប្រណិតកម្រិតពិភពលោក"។ ទី២)ប៉ូលទេសចរណ៍តំបន់អង្កោលជា"តំបន់ទេសចរណ៍ឆ្នេរសមុទ្រធម្មជាតិបែបទំនើប"។ ទី៣)ប៉ូលទេសចរណ៍ធម្មជាតិតំបន់ភ្នំវល្លិ៍ជា "តំបន់កសិទេសចរណ៍និងទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ" និងទី៤)ប៉ូលទេសចរណ៍តំបន់សមុទ្រនិងប្រជុំកោះជា "តំបន់ទេសចរណ៍សមុទ្រកោះប្រណិត"។ ប៉ូលទេសចរណ៍នីមួយៗនឹងត្រូវបានទទួលការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗទៅតាមសក្តានុពលនៃគោលដៅទាំងនោះ ព្រមទាំងមានការរៀបចំព្រឹត្តិការណ៍ថ្មីៗជាមូលដ្ឋានសម្រាប់ការទាក់ទាញភ្ញៀវទេសចរ និងមានការរៀបចំ និងការពង្រឹងយន្តការគាំទ្រនានាផងដែរ។

**ទី២- យុទ្ធសាស្ត្រលើកកម្ពស់ការវិនិយោគនិងផ្សព្វផ្សាយ:** សំដៅទាក់ទាញការវិនិយោគនិងការចូលរួមពីសំណាក់វិស័យឯកជន ក្នុងការអភិវឌ្ឍទេសចរណ៍ខេត្តកែប ព្រមទាំងរៀបចំយន្តការ

ផ្សព្វផ្សាយ ដើម្បីលើកកម្ពស់កិត្តិនាមរបស់ខេត្តកែបជាគោលដៅទេសចរណ៍ប្រកបដោយគុណភាពកម្រិតពិភពលោក។

**ទី៣- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគាំទ្រ:** សំដៅអភិវឌ្ឍវិស័យនានាដែលគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាក្នុងវិស័យទាំងនោះ ដែលក្នុងនោះ រួមមានដូចជាការគ្រប់គ្រងសំណល់រឹងនិងសំណល់រាវ និងការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រសំខាន់ៗ ជាដើម។

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត"**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥**" ផែនការមេនេះបានកំណត់យន្តការអនុវត្ត តាមដាន និងវាយតម្លៃការអនុវត្តយ៉ាងច្បាស់លាស់ ក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងមានគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា ជាស្ថាប័នសម្របសម្រួល ព្រមទាំងមានគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ជាស្ថាប័នទទួលបន្ទុកក្នុងការអនុវត្តផែនការមេ និងមានស្ថាប័នអង្គភាពមួយចំនួនទៀតដែលនឹងគាំទ្រដល់ការអនុវត្តផែនការមេនេះ។ ការអនុវត្តផែនការមេនេះប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានការសហការខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ រួមទាំងក្រសួង ស្ថាប័ន គ្រប់កម្រិត ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងវិស័យឯកជននិងប្រជាពលរដ្ឋក្នុងមូលដ្ឋានផងដែរ។

ដោយសារការអនុវត្តផែនការមេនេះជាកិច្ចការរយៈពេលយូរ ផែនការមេនេះត្រូវបានចាត់ទុកជា "ឯកសាររស់" ដើម្បីធានាភាពសមស្របទៅតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចសង្គម និងស្ថានភាពនៃទីផ្សារ និងវិស័យទេសចរណ៍សកល។

## ១- សេចក្តីផ្តើម

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ និងជាពិសេសការរីកចម្រើនលើគ្រប់វិស័យ ដើម្បីលើកស្ទួយកិត្យានុភាពជាតិទាំងនៅក្នុងតំបន់និងសកលលោក និងជាពិសេសរំដោះប្រជាពលរដ្ឋជាច្រើនគ្រួសារពីភាពក្រីក្រ។ នៅក្នុងរយៈពេលប្រមាណ២ទសវត្សរ៍ចុងក្រោយនេះ សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបានលូតលាស់យ៉ាងលឿន ក្នុងអត្រាជាមធ្យមប្រមាណ៧% ក្នុងមួយឆ្នាំ ដែលនាំឱ្យសកលលោកទាំងមូលចាត់ទុកព្រះរាជាណាចក្រកម្ពុជានៅក្នុងចំណោមប្រទេសដែលលូតលាស់លឿនជាងគេនៅលើសកលលោក។ ជាមួយនិងការអភិវឌ្ឍយ៉ាងលឿននេះ ព្រះរាជាណាចក្រកម្ពុជាបានប្រែក្លាយខ្លួនពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងកំពុងតែសំដៅឆ្ពោះទៅរកការប្រែក្លាយខ្លួនជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។

ក្នុងដំណើរនៃការអភិវឌ្ឍយ៉ាងលឿននេះ វិស័យទេសចរណ៍បានដើរតួជាក្បាលម៉ាស៊ីនយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ដោយពឹងផ្អែកលើធនធានវប្បធម៌ បេតិកភណ្ឌ និងធនធានធម្មជាតិ ដែលអនុញ្ញាតឱ្យមានកំណើនទេសចរណ៍ជារៀងរាល់ឆ្នាំ។ គិតត្រឹមឆ្នាំ២០១៩ មុននឹងការមកដល់នៃវិបត្តិនៃជំងឺកូវីដ-១៩ ចំនួនភ្ញៀវទេសចរអន្តរជាតិបានកើនឡើងរហូតដល់៦,១លាននាក់ ហើយវិស័យទេសចរណ៍ទាំងមូលបានផ្តល់ការងារដល់ប្រជាជនប្រមាណ៦៣ម៉ឺននាក់ និងបានរួមចំណែកប្រមាណ១២,១%នៃផលិតផលក្នុងស្រុកសរុប។ អាស្រ័យហេតុនេះ វិស័យទេសចរណ៍ត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលជាវិស័យអាទិភាព ដោយមិនត្រឹមតែបង្កើតនូវឱកាសការងារ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបង្កើនប្រាក់ចំណូលជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសនិងក្នុងស្រុក ព្រមទាំងរំហូរចូលនៃរូបិយបណ្ណអន្តរជាតិ ដែលជាកត្តារួមចំណែកដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

ជាអកុសល វិបត្តិនៃជំងឺកូវីដ-១៩បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ ដោយសារប្រទេសស្ទើរទាំងអស់បានអនុវត្តនូវវិធានការបិទខ្ទប់ ដែលនាំឱ្យមានការធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិផង និងភ្ញៀវទេសចរក្នុងស្រុកផង។ ដើម្បីលើកស្ទួយវិស័យទេសចរណ៍ និងសង្គមសេដ្ឋកិច្ចទាំងមូល រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការអន្តរាគមន៍ជាច្រើនក្នុងវិស័យទេសចរណ៍និងវិស័យផ្សេងៗទៀត ជាពិសេស ការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដែលអនុញ្ញាតឱ្យមានការបើកសកម្មភាពសង្គមសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័ស។ ស្របជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថាវិបត្តិនៃជំងឺកូវីដ-១៩បាននាំឱ្យមានការប្រែប្រួលក្នុងវិស័យទេសចរណ៍ទូទៅ និងបានផ្តល់នូវកាលានុវត្តភាពថ្មីៗសម្រាប់វិស័យទេសចរណ៍ ដែលក្នុងនោះ រួមមានដូចជានិន្នាការកើនឡើងនៃទេសចរណ៍ធម្មជាតិ ទេសចរណ៍វប្បធម៌ និងទេសចរណ៍សហគមន៍ជាដើម។

ឆ្លើយតបទៅនឹងការប្រែប្រួល និងនិន្នាការថ្មីៗនៅក្នុងវិស័យទេសចរណ៍ និងដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសកល ដូចជាសង្គ្រាមអ៊ុយក្រែន បញ្ហាភូមិសាស្ត្រនយោបាយក្នុងតំបន់ និងភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ចសកលមកលើវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥"** សំដៅប្រែក្លាយខេត្តកែបជាគោលដៅទេសចរណ៍ប្រណិតប្រកបដោយឧត្តមភាពដ៏សំខាន់មួយ និងចាប់យកកាលានុវត្តភាពថ្មីៗក្នុងវិស័យទេសចរណ៍សម្រាប់ជាប្រយោជន៍ជូនដល់ប្រជាពលរដ្ឋក្នុងខេត្តកែបផង និងសម្រាប់វិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាផង។

## ១.១- សាវតារ និងស្ថានភាពនៃវិស័យទេសចរណ៍ខេត្តកែប

ខេត្តកែបមានទីតាំងភូមិសាស្ត្រស្ថិតនៅទិសនិរតីនៃព្រះរាជាណាចក្រកម្ពុជា និងមានព្រំប្រទល់មួយផ្នែកជាប់ខេត្តកំពត និងមួយផ្នែកទៀតជាប់តំបន់ដែនទឹកកម្ពុជាវៀតណាម មានចម្ងាយប្រមាណ១៧៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ខេត្តកែបមានផ្ទៃដីគោកសរុប ១៨៧,២៤គីឡូម៉ែត្រការ៉េ និងត្រូវបានបែងចែកជាស្រុកចំនួន ១ គឺស្រុកដំណាក់ចង្អើរ និងក្រុងចំនួន១ គឺក្រុងកែប។ ខេត្តកែបជាខេត្តក្នុងតំបន់ឆ្នេរ ដែលមានធនធានធម្មជាតិជាច្រើនរួមមានដូចជា កោះចំនួន១២ ថ្មដុះស្លួត ថ្មប៉ប្រះទឹក មានឆ្នេរសមុទ្រ ព្រែក អូរ ព្រៃកោងកាង វាលទំនាប ខ្ពង់រាប និងតំបន់ភ្នំ គម្របព្រៃ និងឧទ្យានជាតិ ជាដើម។

ដោយសារធនធានធម្មជាតិដ៏សម្បូរបែប ខេត្តកែបបានក្លាយជាគោលដៅទេសចរណ៍ដ៏សំខាន់មួយចាប់តាំងពីក្នុងសម័យអាណានិគមនិយមបារាំងមកម្ល៉េះ ដោយក្លាយជាទីពេញនិយមនៃឥស្សរជនបារាំង និងឥស្សរជនខ្មែរ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ក្រុងកែបត្រូវបានបង្កើតឡើងដោយមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងសំណង់ភូមិគ្រឹះនានាតាមរចនាបថខ្មែរ និងស្ថាបត្យកម្មសម័យសង្គមរាស្ត្រនិយម ហើយសំណង់ទាំងនោះមួយចំនួនត្រូវបានបន្សល់មកដល់សព្វថ្ងៃនេះ ជាសម្បត្តិវប្បធម៌យ៉ាងសំខាន់។

មកទល់បច្ចុប្បន្ននេះ ខេត្តកែបមានការអភិវឌ្ឍជឿនលឿនជាលំដាប់ ដោយពឹងផ្អែកលើវិស័យមួយចំនួនជាមូលដ្ឋាននៃសកម្មភាពសង្គមសេដ្ឋកិច្ច ដែលក្នុងនោះ រួមមានវិស័យកសិកម្ម នេសាទ សិប្បកម្ម និងជាពិសេសវិស័យទេសចរណ៍។ មុនវិបត្តិនៃជំងឺកូវីដ-១៩ សកម្មភាពក្នុងវិស័យទេសចរណ៍ខេត្តកែបបានរីកដុះដាលគួរឱ្យកត់សម្គាល់ ដោយមានការកើនឡើងយ៉ាងសកម្មនូវសណ្ឋាគារខ្នាតតូចនិងមធ្យម ផ្ទះសំណាក់វីឡាប្រណិតៗ ភោជនីយដ្ឋាន និងសកម្មភាពសេវាកម្មកម្សាន្តជាច្រើនទៀត។ ត្រឹមដើមឆ្នាំ២០២០ ខេត្តកែបមានសណ្ឋាគារចំនួន១៤កន្លែង ផ្ទះសំណាក់ចំនួន៥៩កន្លែង និងប៊ឹងហ្គាឡូចំនួន២៧កន្លែង ដែលសរុបមាន ២៣០៦បន្ទប់ ព្រមទាំងភោជនីយដ្ឋាននិងអាហារដ្ឋានមានចំនួន ៣៩កន្លែង ស្មើនឹង ២២៦៤តុ។

ក្នុងកំឡុងពេលវិបត្តិជំងឺកូវីដ-១៩ សក្តានុពលរបស់ខេត្តកែបនៅបន្តទាក់ទាញភ្ញៀវទេសចរជាច្រើនមកទស្សនាក្នុងខេត្តនេះ ទោះបីជាមានការធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិក៏ដោយ។ សម្រាប់ឆ្នាំ២០២០ ភ្ញៀវទេសចរក្នុងស្រុកទូទាំងព្រះរាជណាចក្រកម្ពុជាមានចំនួនប្រមាណជិត**៦លាននាក់** ក្នុងនោះតំបន់ឆ្នេរទទួលបានភ្ញៀវទេសចរចំនួន**២,៨៧លាននាក់** រីឯខេត្តកែបទទួលបានការកើនឡើងនៃចំនួនភ្ញៀវទេសចរក្នុងស្រុកដល់

## ១-រូបភាពផែនទីទីតាំងភូមិសាស្ត្រខេត្តកែប







ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្តោយទី១០២អង្សា ដល់ ១០៨អង្សា និងរយៈទទឹងទី១០អង្សា ដល់ ១៥អង្សា។

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១០៣៥គីឡូម៉ែត្រក្រឡា ដែលក្នុងនោះមានបណ្តោយ ៥៦០គីឡូម៉ែត្រ និងទទឹង ៤៤០ គីឡូម៉ែត្រ ព្រមទាំងមានព្រំប្រទល់ដីគោកជាប់ប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាមប្រវែង២១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០គីឡូម៉ែត្រ។




ខេត្តកែបមានព្រំប្រទល់ជាប់នឹងខេត្តកំពត និងសមុទ្រ និងមានផ្ទៃដីគោក ១៨៧,២៤គីឡូម៉ែត្រក្រឡា ព្រមទាំងមានស្រុកចំនួន១ គឺស្រុកដំណាក់ចង្អើរ និងក្រុងចំនួន១ គឺក្រុងកែប។ ខេត្តកែបជាខេត្តក្នុងតំបន់ឆ្នេរ ដែលមានធនធានធម្មជាតិជាច្រើនដូចជា កោះចំនួន១២ ថ្មដុះស្នូត ថ្មប៉ប្រះទឹក មានឆ្នេរសមុទ្រ ព្រៃក អូរ ព្រៃកោងកាង វាលទំនាប ខ្ពង់រាប និងតំបន់ភ្នំ តម្រប់ព្រៃ និងឧទ្យានជាតិជាដើម។

១.៤លាននាក់។ ដោយឡែក សម្រាប់ឆ្នាំ២០២២ តំបន់ឆ្នេរទទួលបានភ្ញៀវទេសចរអន្តរជាតិមកកម្សាន្តមានចំនួនសរុប**៤២៤ ១៨៩**នាក់ កើនឡើង៣០០,៦% ធៀបនឹងឆ្នាំ២០២១ និងភ្ញៀវទេសចរជាតិ មានចំនួនសរុប **៧ ១១៥ ៨៥៦**នាក់ កើនឡើង**២៤៧%** ដែលក្នុងនោះ ខេត្តកែបទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួន **១៩ ៥៥៧**នាក់ កើនឡើង**២២៥,៧៨%** និងភ្ញៀវទេសចរជាតិមានចំនួន **១ ២៩៧ ៤៣២**នាក់ កើនឡើង **១២៣,៥៦%** ធៀបនឹងឆ្នាំ២០២១។

## ១.២- ការសិក្សានិងវិភាគទីផ្សារទេសចរណ៍ខេត្តកែប

ដើម្បីជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តកែប ការសិក្សាមួយត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ២០២០ តាមរយៈការស្ទង់មតិជាមួយភ្ញៀវទេសចរចំនួន៧០០នាក់ និងមូលដ្ឋានអាជីវកម្មទេស-ចរណ៍ចំនួន១០៧ទីតាំង។ ការសិក្សានេះបានបញ្ជាក់យ៉ាងច្បាស់ថា ខេត្តកែបជាគោលដៅដែលមានសក្តានុពលទេសចរណ៍ខ្ពស់ និងអាចត្រូវបានអភិវឌ្ឍបន្ថែមដើម្បីលើកកម្ពស់វិស័យទេសចរណ៍មួយកម្រិតទៀត សម្រាប់ជាប្រយោជន៍ជូនប្រជាជនក្នុងមូលដ្ឋាននិងសម្រាប់រួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងខេត្តនិងតំបន់។

ជាលទ្ធផល ការសិក្សានេះបានបង្ហាញថា ខេត្តកែបជាគោលដៅទេសចរណ៍ដែលមានភាពទាក់ទាញ និងមានសក្តានុពលផ្នែកធនធានធម្មជាតិច្រើន។ ភ្ញៀវទេសចរភាគច្រើនកំណត់ឆ្នេរកែប កោះទន្សាយ និងឧទ្យានជាតិកែប ជាគោលដៅកម្សាន្តចម្បងដែលឆ្លុះបញ្ចាំងថា តំបន់ក្រុងកែបចាស់និងកោះទន្សាយជាទីតាំងប្រមូលផ្តុំសកម្មភាពទេសចរណ៍សំខាន់ៗ។ លើសពីនេះ ភ្ញៀវទេសចរភាគច្រើនមកកម្សាន្តនៅខេត្តកែបម្តងហើយម្តងទៀតក្នុងមួយឆ្នាំ ប៉ុន្តែការសម្រាកកម្សាន្តនេះភាគច្រើនជាការសម្រាកកម្សាន្តរយៈពេលខ្លី ដោយភ្ញៀវទេសចរភាគច្រើនចំណាយពេលត្រឹម១ ទៅ៣ថ្ងៃប៉ុណ្ណោះ។ ជាមួយគ្នានេះផងដែរ ខេត្តកែបជាគោលដៅទេសចរណ៍តាមរដូវកាលដោយមានការកើនឡើងនៃសកម្មភាពទេសចរណ៍នៅក្នុងរដូវក្តៅ និងធ្លាក់ចុះនៅក្នុងរដូវវស្សា។ ការណ៍នេះបង្ហាញថា ខេត្តកែបអាចទទួលបានផលប្រយោជន៍បន្ថែមទៀតពីការពន្យារពេលស្នាក់នៅរបស់ភ្ញៀវទេសចរតាមរយៈការលើកកម្ពស់ផលិតផលទេសចរណ៍ដែលមានស្រាប់ និងអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ សំដៅប្រែក្លាយខេត្តកែបជាប៉ូលទេសចរណ៍សំខាន់មួយ ដើម្បីធានាស្ថិរភាពនិងចីរភាពនៃសកម្មភាពអាជីវកម្ម ព្រមទាំងលើកកម្ពស់ការលូតលាស់នៃវិស័យទេសចរណ៍។

ពាក់ព័ន្ធនឹងផ្នែកអាជីវកម្ម ការសិក្សានេះបានបង្ហាញថា មូលដ្ឋាននិងការលូតលាស់នៃអាជីវកម្មក្នុងខេត្តកែបនៅមានកម្រិត។ អាជីវកម្មភាគច្រើនជាអាជីវកម្មថ្មី ដែលក្នុងនោះ ៧០%បើកដំណើរការក្នុងរយៈពេលតិចជាង៥ឆ្នាំប៉ុណ្ណោះ ហើយអាជីវកម្មរហូតដល់ទៅ៨៦,១៤% ជាប្រភេទអាជីវកម្មខ្នាតតូច ដែលមានបុគ្គលិកត្រឹម ១-១០នាក់ប៉ុណ្ណោះ។ ជាមួយគ្នានេះ លទ្ធផលនៃការស្ទង់មតិរបស់ភ្ញៀវទេសចរបានបង្ហាញថា មានភ្ញៀវទេសចរត្រឹមតែប្រមាណ៥%ប៉ុណ្ណោះ ដែលមកកម្សាន្តនៅខេត្តកែបក្នុងគោលបំណងធុរកិច្ច។ អាស្រ័យហេតុនេះ ការលើកកម្ពស់សក្តានុពលទេសចរណ៍នៃខេត្តកែប និងការអភិវឌ្ឍមូលដ្ឋានអាជីវកម្ម និងទាក់ទាញវិនិយោគ គឺជាកិច្ចការចាំបាច់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៃខេត្តកែប។

ដើម្បីលើកកម្ពស់សក្តានុពលទេសចរណ៍នៃខេត្តកែប និងប្រែក្លាយខេត្តកែបជាគោលដៅទេសចរណ៍ដ៏ប្រណិត ការសិក្សានេះបានបង្ហាញថា ខេត្តកែបមានតម្រូវការក្នុងការអភិវឌ្ឍគោលដៅទេសចរណ៍និងផលិតផលទេសចរណ៍សំខាន់ៗ ព្រមទាំងអភិវឌ្ឍវិស័យគាំទ្រជាច្រើនផ្សេងទៀត។ លទ្ធផលនៃការសិក្សាបានបង្ហាញថា ភ្ញៀវទេសចរជាច្រើនគាំទ្រឱ្យមានការពង្រឹងបន្ថែមលើគោលដៅកម្សាន្តដែលមានស្រាប់ ព្រមទាំងការរៀបចំជាព្រឹត្តិការណ៍ កម្មវិធី និងផលិតផលទេសចរណ៍ថ្មីៗ ដូចជា វិថីម្ហូបអាហារ កន្ត្រកខ្សែកាប (Cable Car) ផ្សាររាត្រី និងសកម្មភាពដំណើរកម្សាន្តតាមទូកជាដើម។ បន្ថែមលើការអភិវឌ្ឍផលិតផលទេសចរណ៍ទាំងនេះ មូលដ្ឋានអាជីវកម្មភាគច្រើនស្នើឱ្យមានការអភិវឌ្ឍលើវិស័យគាំទ្រនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀតផងដែរ ពាក់ព័ន្ធទៅនឹងសន្តិសុខ សុវត្ថិភាព និងការគ្រប់គ្រងសំណល់រឹងនិងសំណល់រាវជាដើម។

## ១.៣- សក្តានុពលនៃវិស័យទេសចរណ៍ខេត្តកែប

ខេត្តកែបមានធនធានជាច្រើន ដែលជាសក្តានុពលយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ និងជាទុនយ៉ាងសំខាន់សម្រាប់ការប្រែក្លាយខេត្តកែប ឱ្យទៅជាគោលដៅទេសចរណ៍បែបធម្មជាតិប្រណិតកម្រិតខ្ពស់។ ធនធានទាំងនោះរួមមានដូចជា ធនធានធម្មជាតិនិងបរិស្ថានក្នុងតំបន់ឧទ្យានជាតិកែប តំបន់ឆ្នេរ និងតំបន់កោះ ដែលប្រមូលផ្តុំទៅដោយជីវៈចម្រុះ និងជាមូលដ្ឋានសម្រាប់អភិវឌ្ឍវិស័យអេកូទេសចរណ៍ វិស័យកសិកម្ម នេសាទ និងសិប្បកម្ម ដែលមានអំណោយផលពីធម្មជាតិ និងសម្រាប់អភិវឌ្ឍវិស័យកសិទេសចរណ៍ និងសំណង់បេតិកភណ្ឌនិងបុរាណដ្ឋានជាច្រើន ដែលជាមូលដ្ឋានក្នុងការទាក់ទាញទេសចរណ៍បែបប្រវត្តិសាស្ត្រនិងវប្បធម៌។

ពាក់ព័ន្ធនឹងធនធានធម្មជាតិនិងបរិស្ថាន ខេត្តកែបត្រូវបានទទួលស្គាល់ថា ជាខេត្តពោរពេញដោយសក្តានុពល និងត្រូវបានវាយតម្លៃនិងទទួលបានងារជាខេត្តនិរន្តរភាពបរិស្ថានអាស៊ាន និងជាទីក្រុងឈានមុខអាស៊ាននៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព។ ក្នុងន័យនេះ ធនធានធម្មជាតិនិងបរិស្ថាន នឹងដើរតួនាទីជាផលិតផលទេសចរណ៍ស្នូលក្នុងការទាក់ទាញភ្ញៀវទេសចរ។ ធនធានធម្មជាតិសំខាន់ៗ មានដូចជា ឧទ្យានជាតិកែបនៅចំកណ្តាលក្រុងកែប ដែលមានទំហំរហូតដល់១១៥២ហិកតា និងពោរពេញទៅដោយជីវៈចម្រុះដ៏សម្បូណ៌បែប ដូចជារុក្ខជាតិចម្រុះ ព្រៃឈើធំៗ ព្រមទាំងសត្វព្រៃជាច្រើនប្រភេទ ជាពិសេសប្រភេទសត្វជិតផុតពូជមួយចំនួន ដូចជាកេងកង ទោច និងអកសមុទ្រ ដែលធនធានទាំងអស់នេះបានទាក់ទាញទាំងភ្ញៀវទេសចរជាតិនិងអន្តរជាតិ មកទស្សនាផងនិងសិក្សាស្រាវជ្រាវផង។ ក្រៅពីនេះ ខេត្តកែបមានកោះជាច្រើន ដូចជា កោះទន្សាយ និងប្រជុំកោះពោធិ៍ ដែលផ្តល់នូវបរិស្ថាននិងបរិយាកាសនៃជំនោរសមុទ្រមួយបែបផ្សេងទៀត ដែលប្រមូលផ្តុំទៅដោយជីវៈចម្រុះមួយបែបទៀត និងមានសក្តានុពលក្នុងការអភិវឌ្ឍផលិតផល និងសកម្មភាពទេសចរណ៍ថ្មីៗបន្ថែមទៀត ដូចជាទេសចរណ៍មុជក្រោមសមុទ្រ និងសកម្មភាពកម្សាន្តផ្សេងៗទៀតលើផ្ទៃសមុទ្រ ជាដើម។

វិស័យកសិកម្មនិងនេសាទក្នុងខេត្តកែបមានអំណោយផលល្អពីធម្មជាតិ ដោយមានប្រជាជនប្រមាណ៧៦,៦% ប្រកបរបរកសិកម្ម ដែលភាគច្រើនធ្វើស្រែចំការ ដាំដុះដំណាំ ចិញ្ចឹមសត្វ នេសាទ វារីវប្បកម្ម ការអភិរក្សធនធានជលផល និងការពារធនធានព្រៃឈើនិងសត្វព្រៃ។ ពាក់ព័ន្ធនឹងគ្នានេះដែរ ខេត្តកែបក៏សម្បូណ៌ទៅដោយសកម្មភាពសិប្បកម្មចំណីអាហារ ដែលជាខ្សែច្រវាក់ផលិតកម្មបន្តពីវិស័យកសិកម្មនិងនេសាទ ដូចជាសិប្បកម្មកែច្នៃផលិតផលសមុទ្រ សិប្បកម្មផលិតទឹកត្រី និងសិប្បកម្មផ្សេងៗជាច្រើនទៀត ជាពិសេស ផលិតកម្មអំបិលសម្រាប់ផ្គត់ផ្គង់ដល់ភ្ញៀវទេសចរ ព្រមទាំងប្រជាជននិងអាជីវកម្មក្នុងមូលដ្ឋាន។ សកម្មភាពទាំងអស់នេះក៏មានសក្ដានុពលយ៉ាងខ្លាំងក្លាក្នុងការអភិវឌ្ឍវិស័យកសិទេសចរណ៍ ដើម្បីបើកឱ្យមានប្រភពចំណូលបន្ថែមសម្រាប់កសិករនិងសិប្បករ ព្រមទាំងលើកកម្ពស់ជីវភាពកសិករបន្ថែម និងពង្រីកមូលដ្ឋាននៃវិស័យទេសចរណ៍ក្នុងខេត្តកែប។

ជាមួយគ្នានេះផងដែរ ប្រវត្តិសាស្ត្រនិងសាវតាររបស់ខេត្តកែបបានបន្សល់ទុកនូវវត្តអារាម មណ្ឌលសាសនានិងសមាធិ និងធនធានបេតិកភណ្ឌនិងវប្បធម៌ជាច្រើន ដែលជាសម្បត្តិវប្បធម៌ដ៏មានតម្លៃដូចជា ព្រះរាជដំណាក់នៅពយដំណាក់ស្ដេច សំណង់បេតិកភណ្ឌនិងផែបុរាណនៅជិតកំពង់ផែចាស់ សំណង់អតីតផ្ទះទឹមដុង ភ្នំសសៀរ និងសំណង់បុរាណនានាក្នុងក្រុងកែប។ សម្បត្តិវប្បធម៌ទាំងអស់នេះ គឺជាធនធាន និងទុនយ៉ាងសំខាន់ ដែលបានទាក់ទាញការទស្សនានិងសិក្សាស្រាវជ្រាវយ៉ាងច្រើន និងអាចត្រូវបានអភិវឌ្ឍបន្ថែម ដើម្បីពង្រឹងសក្ដានុពលនៃធនធានទាំងនេះបន្ថែមទៀត។

## ១.៤- ស្ថានភាពនៃវិស័យគាំទ្រពាក់ព័ន្ធនឹងវិស័យទេសចរណ៍ខេត្តកែប

ការអភិវឌ្ឍវិស័យទេសចរណ៍តម្រូវឱ្យមានការគាំទ្រពីវិស័យពាក់ព័ន្ធផ្សេងៗទៀតជាច្រើន។ សម្រាប់ខេត្តកែប វិស័យគាំទ្រមួយចំនួនមានស្ថានភាពល្អប្រសើរដែលអាចទ្រទ្រង់ដល់ការកើនឡើងនៃចំនួនភ្ញៀវទេសចរ ខណៈដែលវិស័យមួយចំនួននៅមានភាពខ្វះខាត និងទាមទារឱ្យមានការអភិវឌ្ឍបន្ថែម។ ជារួម ស្ថានភាពនៃវិស័យគាំទ្រសំខាន់ៗ មានដូចខាងក្រោម÷

### ➢ វិស័យសន្តិសុខ

វិស័យសន្តិសុខ គឺជាកត្តាចម្បងក្នុងការទាក់ទាញ និងផ្ដល់ទំនុកចិត្តទៅដល់ភ្ញៀវទេសចរនិងវិនិយោគិន ព្រមទាំងប្រជាជនក្នុងមូលដ្ឋាន។ នៅក្នុងបរិបទបច្ចុប្បន្ន កងកម្លាំងមានសមត្ថកិច្ចបានយកចិត្តទុកដាក់បំពេញភារកិច្ចបានល្អនៅតាមគោលដៅសំខាន់ៗ។ ប៉ុន្តែ ដើម្បីត្រៀមខ្លួនទទួលភ្ញៀវទេសចរជាទ្រង់ទ្រាយធំ និងប្រកបដោយគុណភាព ខេត្តកែបនៅមានជួបបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះចំនួនកម្លាំងសមត្ថកិច្ច កង្វះមន្ត្រីនគរបាលចេះភាសាបរទេសនិងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើប ព្រមទាំងកង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជាភ្លើងបំភ្លឺនៅពេលយប់នៅតាមទីសាធារណៈជាដើម។

- **វិស័យសុខាភិបាល**

ពាក់ព័ន្ធនឹងវិស័យសុខាភិបាល ខេត្តកែបអាចផ្តល់សេវាកម្មបានល្អបង្គួរដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ប៉ុន្តែនៅពុំទាន់ឆ្លើយតបតាមតម្រូវការបានពេញលេញនៅឡើយទេ ជាពិសេសក្នុងករណីដែលមានការកើនឡើងនៃចំនួនភ្ញៀវទេសចរ វិនិយោគិន និងប្រជាជននៅក្នុងមូលដ្ឋាន។ ក្នុងនោះ ខេត្តកែបកំពុងជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដូចជាកង្វះគ្រូពេទ្យឯកទេស គិលានុបដ្ឋាយិកា សម្ភារៈបរិក្ខារពេទ្យ និងសមត្ថភាពមន្ទីរពិសោធន៍នៅមានកម្រិត។ ហេតុនេះ ដើម្បីត្រៀមខ្លួនសម្រាប់ការទទួលភ្ញៀវទេសចរជាលក្ខណៈទ្រង់ទ្រាយធំ ជាពិសេស ដើម្បីចូលរួមគាំទ្រដល់ការសម្រាកលំហែបែបប្រណិតរយៈពេលវែង ខេត្តកែបចាំបាច់ត្រូវលើកកម្ពស់ និងធ្វើទំនើបកម្មវិស័យសុខាភិបាលបន្ថែមទៀត។

- **ការគ្រប់គ្រងសំណល់រឹងនិងសំណល់រាវ**

បច្ចុប្បន្ន ខេត្តកែបនៅជួបប្រទះនឹងបញ្ហាមួយចំនួនពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់រឹងដោយសារអត្រានៃការកើនឡើងនៃសំណល់រឹងមានកម្រិតខ្ពស់ជាងសមត្ថភាពប្រមូលជាក់ស្តែង។ បញ្ហានេះគឺបណ្តាលមកពីកង្វះបច្ចេកទេសនិងមធ្យោបាយប្រមូលសំណល់រឹង និងកង្វះការយល់ដឹងនិងការទទួលខុសត្រូវរបស់ប្រជាជនក្នុងមូលដ្ឋាននិងភ្ញៀវទេសចរមួយចំនួន ។ ដោយឡែក ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រាវ ខេត្តកែបជួបប្រទះនឹងបញ្ហាប្រឈម ដោយសារការបញ្ចេញសំណល់រាវមានកម្រិតខ្ពស់ ក្នុងខណៈដែលខេត្តកែបពុំមានអាងប្រព្រឹត្តកម្មទឹកកខ្វក់គ្រប់គ្រាន់។ លើសពីនេះ ដោយសារខេត្តកែបពុំទាន់មានប្រព័ន្ធលូដែលមានការបែងចែកឱ្យដាច់រវាងលូទឹកភ្លៀងនិងលូទឹកកខ្វក់នៅឡើយ សំណល់រាវចេញពីមូលដ្ឋានអាជីវកម្ម ក៏ដូចជាពីលំនៅឋាន ត្រូវហូរចូលដោយផ្ទាល់ទៅក្នុងធម្មជាតិ ដែលនាំឱ្យប៉ះពាល់ដល់ធនធានធម្មជាតិនិងបរិស្ថានទាំងមូល។ ហេតុដូចនេះ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំណល់រឹងនិងសំណល់រាវក្នុងខេត្តកែបពិតជាកត្តាគន្លឹះសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប ជាគោលដៅទេសចរណ៍ធម្មជាតិសម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់និងប្រកបដោយចីរភាព។

- **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តកែបកំពុងយកចិត្តទុកដាក់យ៉ាងសកម្មក្នុងការគ្រប់គ្រងនិងទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ទប់ស្កាត់ភាពអនាធិបតេយ្យជំរុញអនុលោមភាពសំណង់ ជំរុញការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ រៀបចំប្លង់គោលក្រុងនិងស្រុកដោះស្រាយបញ្ហាដីធ្លីក្រៅប្រព័ន្ធតុលាការ និងចូលរួមកំណត់ព្រំដីព្រៃកោងកាង។ ទោះបីមានការប្រឹងប្រែងយ៉ាងនេះក្តី ខេត្តកែបនៅជួបប្រទះនឹងបញ្ហាផ្សេងៗទៀតមួយចំនួនដែលទាមទារឱ្យមានដំណោះស្រាយ ដូចជាការទុកដីឡូត៍ចោលមិនប្រើប្រាស់ ការមិនទាន់កំណត់ប្រភេទនគរូបនីយកម្មនៃសំណង់ក្នុងខេត្តច្បាស់លាស់ការទន្ទ្រានដីព្រៃកោងកាង និងការលួចលាក់ចាក់ដីលុបព្រែកនិងអូរដោយខុសច្បាប់ ជាដើម។

➢ **ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍**

បច្ចុប្បន្ន ខេត្តកែបមានបណ្តាញផ្លូវថ្នល់ ដែលជាប្រភេទផ្លូវជាតិ ផ្លូវខេត្ត ផ្លូវក្នុងក្រុង និងផ្លូវលំជនបទសរុបប្រវែង៩១,០៩គ.ម។ ក្នុងនោះ ផ្លូវមួយចំនួនមានព្រៃដុះទ្រុបទ្រុល និងត្រូវបានខូចខាតដោយសារទឹកជំនន់ និងកង្វះប្រព័ន្ធលូបង្ហូរទឹកត្រឹមត្រូវ។ ទោះបីជាថ្មីៗនេះ ផ្លូវសំខាន់ៗមួយចំនួនត្រូវបានពង្រីក ហើយចំណតរថយន្តសម្រាប់រថយន្តក្រុងនិងរថយន្តទេសចរណ៍ជាច្រើនកន្លែងត្រូវបានសាងសង់រួចហើយក្តី បញ្ហាកកស្ទះចរាចរណ៍នៅបន្តមាននៅពេលមានភ្ញៀវទេសចរច្រើនកុះករ ជាពិសេសនៅក្នុងអំឡុងពេលបុណ្យជាតិនិងព្រឹត្តិការណ៍ផ្សេងៗ។ លើសពីនេះ ការរំលោភដីចំណីផ្លូវ ដូចជាការសាងសង់តូបអាជីវកម្ម ការចាក់ដីលុបប្រព័ន្ធផ្លូវទឹកហូរ នៅតែជាបញ្ហាប្រឈមដែលបង្កឱ្យមានការកកស្ទះតាមផ្លូវនិងភាពអនាធិបតេយ្យ។

ជាមួយគ្នានេះផងដែរ ក្នុងនាមជាគោលដៅទេសចរណ៍តំបន់ឆ្នេរ ដែលមានបណ្តុំកោះមួយចំនួនជាប៉ូលទេសចរណ៍ដ៏សំខាន់ ខេត្តកែបត្រូវការកំពង់ផែទេសចរណ៍ប្រកបដោយគុណភាពនិងជាសុកភាព។ បច្ចុប្បន្ន ខេត្តកែបមានកំពង់ផែទេសចរណ៍ចំនួនមួយ គឺកំពង់ផែទេសចរណ៍កោះទន្សាយនៅលើដែនដីគោកនៃខេត្តកែប ខណៈដែលកំពង់ផែទេសចរណ៍មួយទៀតនៅលើកោះទន្សាយផ្ទាល់ កំពុងត្រូវបានធ្វើការសាងសង់ផងដែរ។ ប៉ុន្តែ ក្រៅពីកំពង់ផែទាំងនេះ ខេត្តកែបនៅមិនទាន់មានកំពង់ផែទេសចរណ៍នៅគោលដៅទេសចរណ៍សំខាន់ៗមួយចំនួនទៀតនៅឡើយទេ ដែលក្នុងនោះរួមមានដូចជាតំបន់ប្រជុំកោះពោធិ៍ដែលជាគោលដៅមានសក្តានុពលខ្ពស់។

➢ **វិស័យរ៉ែ**

នាពេលបច្ចុប្បន្ន ដើម្បីបម្រើដល់ការអភិវឌ្ឍនៃវិស័យសំណង់ អគារ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ខេត្តកែបមានអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មចំនួន១៤ និងអាជីវកម្មអាចម៍ដីលើដីឯកជនចំនួន ២ទីតាំង។ ដើម្បីចៀសវាងផលប៉ះពាល់លើទីតាំងដែលមានសក្តានុពលទេសចរណ៍មួយចំនួន រាជរដ្ឋាភិបាលបានកំណត់ទីតាំងសម្រាប់អាជីវកម្មធនធានរ៉ែក្នុងខេត្តកែបចំនួន ៥តំបន់ រួមមាន÷ តំបន់ភ្នំព្រះ តំបន់ប្រហប់ពួហឿន តំបន់ទីលានចាក់សំរាម តំបន់អ្នកតាឈរ និងតំបន់អូរក្មុង (ដូចមានផែនទីក្នុងរូបភាពទី១៣ ទំព័រទី៧៧) និងតំបន់ពុំអនុញ្ញាតឱ្យមានអាជីវកម្មធនធានរ៉ែ មានដូចជា តំបន់ភ្នំពោន តំបន់ភ្នំអង្កោល តំបន់ភ្នំវល្លិ៍ផ្នែកខាងមុខ និងតំបន់សក្តានុពលទេសចរណ៍ធម្មជាតិផ្សេងៗទៀត។

➢ **ការផ្គត់ផ្គង់អគ្គិសនី**

ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តកែបត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ ជាមួយនិងការតភ្ជាប់នូវបណ្តាញអគ្គិសនីពីអនុស្ថានីយផ្សេងៗ ដូចជាអនុស្ថានីយខេត្តកំពតនិងឈូក ដែលមានសមត្ថភាពផ្គត់ផ្គង់អគ្គិសនីសរុបប្រមាណ ១០០មេហ្គាវ៉ាត់ និងការនាំចូលអគ្គិសនីពីប្រទេសវៀតណាមដែលមានអានុភាព២០មេហ្គាវ៉ាត់។ លើសពីនេះ ជាមួយនឹងការអភិវឌ្ឍបណ្តាញបញ្ជូនរងនិងបណ្តាញចែកចាយអគ្គិសនីនៅក្នុងខេត្ត ខេត្តកែបមាន

ប្រព័ន្ធបណ្តាញចែកចាយអគ្គិសនីដល់គ្រប់មូលដ្ឋាននៅក្នុងខេត្ត។ ប៉ុន្តែ ក្នុងគោលដៅអភិវឌ្ឍខេត្តកែបជាប៉ូលទេសចរណ៍សំខាន់មួយ ការផ្គត់ផ្គង់អគ្គិសនីនឹងត្រូវបានពង្រឹងបន្ថែមទៀត ដើម្បីធានាលទ្ធភាពក្នុងការទ្រទ្រង់ដល់ការកើនឡើងនៃភ្ញៀវទេសចរ និងការកើនឡើងនៃសកម្មភាពទេសចរណ៍ ។

➢ **វិស័យផ្គត់ផ្គង់ទឹកស្អាត**

បច្ចុប្បន្ន ខេត្តកែបមានក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតចំនួនពីរ ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចែកចាយដល់ប្រជាជនទាំងអស់នៅក្នុងក្រុងកែបនិងនៅស្រុកដំណាក់ចង្អើរ។ បច្ចុប្បន្ន ការតបណ្តាញទុយយោមេត្រូវបានសម្រេច៨៥%នៅក្នុងក្រុងកែប និង៧០%នៅស្រុកដំណាក់ចង្អើរ។ រាជរដ្ឋាភិបាលមានទិសដៅតបណ្តាញទុយយោមេឱ្យបានគ្រប់ផ្លូវទាំងអស់ទូទាំងក្រុងកែបនិងស្រុកដំណាក់ចង្អើរ នៅត្រឹមឆ្នាំ២០២៥ ដើម្បីសម្រួលឱ្យប្រជាជនទាំងអស់អាចតភ្ជាប់និងប្រើប្រាស់ទឹកស្អាតនេះបាន។ ទោះជាយ៉ាងនេះក្តី ខេត្តកែបពុំទាន់មានប្រភពទឹកយុទ្ធសាស្ត្រ ដែលអាចទ្រទ្រង់ដល់ការអភិវឌ្ឍនិងការរីកចម្រើននៃខេត្តកែបនាពេលអនាគតនៅឡើយទេ។

➢ **វិស័យធនធានទឹក និងការគ្រប់គ្រងទឹកជំនន់**

ខេត្តកែប មានទំនប់ទឹកសរុបចំនួន ១១ ក្នុងនោះទំនប់ទឹកដែលធានាទឹកបាននៅខែប្រាំងមានចំនួន ៨ ដែលអាចស្រោចស្រពដំណាំកសិកម្មផង និងផ្គត់ផ្គង់ទឹកសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនក្នុងតំបន់ផង។ ប៉ុន្តែខេត្តកែបនៅមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងជំនន់ទឹកភ្លៀងនៅឡើយទេ ដោយតំបន់អង្គោលមួយផ្នែកធំនិងតំបន់ក្រុងកែបមួយផ្នែកតូច មានបញ្ហាប្រឈមនឹងគ្រោះជំនន់ទឹកភ្លៀងជាប្រចាំ។ អាស្រ័យហេតុនេះ ការស្វែងរកដំណោះស្រាយសម្រាប់គ្រប់គ្រងជំនន់ទឹកភ្លៀងគឺជាកិច្ចការចាំបាច់ ដើម្បីធានាចីរភាពនៃការអភិវឌ្ឍគោលដៅទេសចរណ៍សំខាន់ៗ។

➢ **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍**

ទោះបីជាមានការអភិវឌ្ឍជាបន្តបន្ទាប់ក្តី ខេត្តកែបនៅមានការខ្វះខាតនិងបញ្ហាប្រឈមផ្នែកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍និងប្រៃសណីយ៍មួយចំនួន ដោយបណ្តាញប្រៃសណីយ៍ និងសេវាកម្មប្រៃសណីយ៍នៅក្នុងភូមិសាស្ត្រខេត្តកែបនៅមានកម្រិត ហើយសេវាទូរសព្ទនិងសេវាអ៊ីនធឺណិតក៏នៅមានភាពខ្វះខាតនៅតំបន់មួយចំនួន ដែលនាំឱ្យមានការលំបាកក្នុងការសម្រួលការប្រាស្រ័យទាក់ទង និងការស្នាក់នៅរបស់ប្រជាពលរដ្ឋ រួមទាំងភ្ញៀវទេសចរ។ អាស្រ័យហេតុនេះ ខេត្តកែបត្រូវមានការអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីលើកកម្ពស់បទពិសោធរបស់ភ្ញៀវទេសចរ និងសម្រួលដល់ការប្រាស្រ័យទាក់ទងរបស់ប្រជាជន ក៏ដូចជាវិនិយោគិនក្នុងមូលដ្ឋាន។

## ១.៥- ការវិភាគលើស្ថានភាពទេសចរណ៍ខេត្តកែបបច្ចុប្បន្ន (ឆ្នាំ២០២២)

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| - ខេត្តកែបមានសក្តានុពលធម្មជាតិ បេតិកភណ្ឌ និងប្រវត្តិសាស្ត្រច្រើន ដែលជាទុនសម្រាប់អភិវឌ្ឍនិងទាក់ទាញភ្ញៀវទេសចរ<br>- ខេត្តកែបមានកិត្យានុភាពនិងមានអំណោយផលពីធម្មជាតិ ក្នុងការអភិវឌ្ឍជាគោលដៅទេសចរណ៍បែបធម្មជាតិ និងកសិទេសចរណ៍<br>- សហគមន៍និងអាជីវកម្មភាគច្រើន មានស្មារតីចូលរួមនិងអភិវឌ្ឍខ្លួនឯង ក៏ដូចជាចូលរួមអភិវឌ្ឍគោលដៅទេសចរណ៍ខេត្តទាំងមូល<br>- ខេត្តកែបមានទីតាំងជិតគោលដៅទេសចរណ៍សំខាន់ៗផ្សេងទៀត និងអាចទាញយកប្រយោជន៍ពីគោលដៅទាំងនោះបាន។ | - ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដូចជាហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ មន្ទីរពេទ្យ ការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ មិនទាន់មានគុណភាពឬសមត្ថភាពគ្រប់គ្រាន់សម្រាប់ការកើនឡើងនៃភ្ញៀវទេសចរជាពិសេស ទេសចរពិសេស<br>- ការផ្តល់សេវាកម្មទេសចរណ៍ដោយស្ថាប័នសាធារណៈនិងឯកជន នៅមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ និងមិនទាន់មានគុណភាពគ្រប់គ្រាន់<br>- ការរៀបចំគោលដៅកម្សាន្តនិងផលិតផលទេសចរណ៍នានា នៅមិនទាន់មានភាពទាក់ទាញនិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារទេសចរណ៍ និង<br>- កង្វះខាតធនធានមនុស្សនិងបុគ្គលិកជំនាញក្នុងវិស័យទេសចរណ៍។ |

| ឱកាស | ប្រឈម |
|---|---|
| - សក្តានុពលរបស់ខេត្តកែបមានភាពសមស្រប ទៅនឹងនិន្នាការថ្មីៗនៃទីផ្សារទេសចរណ៍ ដូចជាការកើនឡើងនៃទេសចរណ៍ក្នុងស្រុក និងការកើនឡើងនៃការពេញនិយមលើវិស័យអេកូទេសចរណ៍ កសិទេសចរណ៍ និងទេសចរណ៍សហគមន៍ ជាដើម<br>- ខេត្តកែបនៅមានសក្តានុពលទេសចរណ៍ច្រើន ដែលមិនទាន់ត្រូវបានកែច្នៃនិងអាចត្រូវបានអភិវឌ្ឍបន្ថែម<br>- ការអភិវឌ្ឍកំពង់ផែទេសចរណ៍អន្តរជាតិខេត្តកំពត និងការអភិវឌ្ឍច្រករបៀងទេសចរណ៍អាស៊ានភាគខាងត្បូង ជាឱកាសជំរុញការវិនិយោគនិងទាក់ទាញភ្ញៀវទេសចរក្នុងតំបន់។ | - ភាពមិនប្រាកដប្រជានិងអស្ថិរភាពនៃស្ថានភាពភូមិសាស្ត្រនយោបាយសកល នៅចោទជាហានិភ័យសម្រាប់ស្ថានភាពសេដ្ឋកិច្ចជាតិនិងសកម្មភាពទេសចរណ៍<br>- ទីផ្សារអចលនវត្ថុនៅក្នុងខេត្តកែបមានភាពមិនប្រាកដប្រជាខ្ពស់ ដែលអាចនាំឱ្យមានការលំបាក ក្នុងការទាក់ទាញនិងលើកកម្ពស់ការវិនិយោគ និង<br>- ខេត្តកែបប្រឈមនឹងការប្រកួតប្រជែងខ្លាំងពីសំណាក់គោលដៅទេសចរណ៍ប្រណិតនៃប្រទេសជិតខាង។ |

## ២- ចក្ខុវិស័យ គោលបំណង និងគោលដៅ

### ២.១- ចក្ខុវិស័យ

ដោយផ្អែកលើសក្តានុពលនៃធនធានធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្ររបស់ខេត្តកែប **“ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥”** បានកំណត់ចក្ខុវិស័យប្រែក្លាយខេត្តកែបជា***“គោលដៅទេសចរណ៍ធម្មជាតិនិងសមុទ្រសម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់”*** ដោយប្រកាន់យកគោលការណ៍នៃការអភិវឌ្ឍប្រកបដោយ *ចីរភាព សុវត្ថិភាព គុណភាព ភាពប្រកួតប្រជែង និងទេសចរណ៍បែបឆ្លាតវៃ។*

### ២.២- គោលបំណង

ជាមួយនិងចក្ខុវិស័យខាងលើ **“ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥”** មានគោលបំណងយុទ្ធសាស្ត្រចម្បងៗចំនួន៣ ដូចខាងក្រោម÷

- ទី១- ប្រែក្លាយខេត្តកែបជាគោលដៅទេសចរណ៍ធម្មជាតិ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទីពីរ ប្រកបដោយផាសុខភាព សុវត្ថិភាព ភាពទាក់ទាញ និងភាពប្រកួតប្រជែងខ្ពស់លើឆាកអន្តរជាតិ
- ទី២- ប្រែក្លាយខេត្តកែបជាគោលដៅទេសចរណ៍សម្រាប់ការស្នាក់កម្សាន្តរយៈពេលយូរនិងគ្រប់រដូវកាល និង
- ទី៣- ធានាការបែងចែកផលសេដ្ឋកិច្ច និងលើកស្ទួយកម្រិតជីវភាពនិងសុខុមាលភាពប្រជាពលរដ្ឋ នៅតាមមូលដ្ឋានប្រកបដោយប្រសិទ្ធភាព សមធម៌ និងបរិយាបន្ន។

### ២.៣- គោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងខាងលើ **“ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥”** ត្រូវបានដាក់ចេញនូវគោលដៅចំនួន៣ ដូចខាងក្រោម ÷

- ទី១- ការអភិវឌ្ឍប៉ូលទេសចរណ៍ខេត្តកែប
- ទី២- ការលើកកម្ពស់ការវិនិយោគ អភិវឌ្ឍធនធានមនុស្ស និងផ្សព្វផ្សាយទីផ្សារ និង
- ទី៣- ការអភិវឌ្ឍវិស័យគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ខេត្តកែប។

## ៣-ក្របខ័ណ្ឌយុទ្ធសាស្ត្រ

### ៣.១- យុទ្ធសាស្ត្រអភិវឌ្ឍន៍ប៉ូលទេសចរណ៍ខេត្តកែប

ការកំណត់និងបែងចែកប៉ូលអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងខេត្តកែប ប្រកបដោយប្រសិទ្ធភាពខ្ពស់ ត្រូវផ្អែកទៅលើកត្តាសំខាន់ៗចំនួន៥ រួមមាន÷ **ក)**-ទីតាំងភូមិសាស្ត្រនិងការគ្រប់គ្រងរដ្ឋបាល **ខ)**-សេដ្ឋកិច្ច **គ)**-ហេដ្ឋារចនាសម្ព័ន្ធគោលនិងបណ្តាញតភ្ជាប់ **ឃ)**-សក្តានុពល និងការផ្គត់ផ្គង់ផលិតផលទេសចរណ៍ និង **ង)**-បរិស្ថាននិងធនធានធម្មជាតិ។ ផ្អែកលើកត្តាទាំង៥ខាងលើ ការអភិវឌ្ឍទេសចរណ៍ខេត្តកែបត្រូវបានកំណត់បង្កើតជាប៉ូលទេសចរណ៍សំខាន់ៗចំនួន៤ រួមមានៈ **ទី១**-ប៉ូលទេសចរណ៍តំបន់ទីក្រុងធម្មជាតិកែប **ទី២**- ប៉ូលទេសចរណ៍បៃតងតំបន់អង្កោល **ទី៣**-ប៉ូលទេសចរណ៍ធម្មជាតិតំបន់ភ្នំវល្លិ៍ និង**ទី៤**-ប៉ូលទេសចរណ៍តំបន់សមុទ្រ និងប្រជុំកោះ។

**រូបភាពទី២: ការកំណត់ប៉ូលទេសចរណ៍ទាំងបួនក្នុងខេត្តកែប**



### ៣.១.១- ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់ទីក្រុងធម្មជាតិកែបជា "ទីក្រុងធម្មជាតិក្នុងឧទ្យានប្រណិតកម្រិតពិភពលោក"

ស្របតាមសក្តានុពលរបស់ក្រុងកែបចាស់ដែលមានឧទ្យានជាតិកែប និងមានសំណង់វប្បធម៌ និងបេតិកភណ្ឌច្រើន រាជរដ្ឋាភិបាលនឹងប្រែក្លាយប៉ូលទេសចរណ៍តំបន់ទីក្រុងធម្មជាតិកែបជា**"ទីក្រុងធម្មជាតិក្នុងឧទ្យានប្រណិតកម្រិតពិភពលោក"** ដើម្បីទាក់ទាញទាំងភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ ការសម្រេចឱ្យបាននូវចក្ខុវិស័យសម្រាប់តំបន់នេះ តម្រូវឱ្យមានការកែលម្អផលិតផលទេសចរណ៍ដែលមានស្រាប់ ដូចជាតំបន់ផ្សារក្តាម ឆ្នេរកែប និងឧទ្យានជាតិកែបជាដើម និងអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ អមដោយការរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា។ ក្នុងន័យនេះ ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់ទីក្រុងធម្មជាតិកែប នឹងត្រូវបានធ្វើឡើងតាមរយៈវិធានការ ដូចខាងក្រោម ៖

➢ **ការអភិវឌ្ឍទេសចរណ៍ធម្មជាតិកម្រិតខ្ពស់ក្នុងឧទ្យានជាតិកែប**

- ជំរុញការវិនិយោគគម្រោងអភិវឌ្ឍន៍អេកូទេសចរណ៍គុណភាពនៅក្នុងឧទ្យានជាតិកែប ដែលទទួលបានគោលការណ៍វិនិយោគរួច ក្នុងទម្រង់ជារមណីយដ្ឋានឬសណ្ឋាគារកម្រិតស្តង់ដាយ៉ាងតិចផ្កាយបួន
- ពង្រឹងការទទួលខុសត្រូវរបស់គម្រោងវិនិយោគទេសចរណ៍ក្នុងឧទ្យានជាតិកែប ស្របតាមគោលការណ៍នៃការកំណត់តំបន់ប្រើប្រាស់ប្រកបដោយចីរភាព ដោយបន្សុំទៅនឹងបទប្បញ្ញត្តិនគរូបនីយកម្ម សម្រាប់ការអភិរក្ស អភិវឌ្ឍ និងសាងសង់ក្នុងក្របខ័ណ្ឌតំបន់ឆ្នេរ ជាពិសេសប្លង់គោលប្រើប្រាស់ដីក្រុងកែប
- ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ដែលគាំទ្រដល់វិស័យទេសចរណ៍ ដូចជាមណ្ឌលព័ត៌មាន ផ្លូវ ស្លាកសញ្ញា និងមគ្គុទ្ទេសក៍ឧទ្យានជាតិជាដើម
- ការពារនិងកែលម្អអាងស្តុកទឹកប៉ោហេងនិងតំបន់ផ្ទៃរងទឹកភ្លៀង សម្រាប់រៀបចំជាគោលដៅកម្សាន្ត និងជាប្រភពទឹកយុទ្ធសាស្ត្រសម្រាប់ការផ្គត់ផ្គង់ទឹកក្នុងប៉ូលទេសចរណ៍តំបន់ក្រុងកែបចាស់ និងជាប្រភពទឹកសម្រាប់គាំទ្រដល់ការរស់នៅរបស់សត្វនិងជីវៈចម្រុះនានានៅក្នុងតំបន់ឧទ្យានជាតិកែប
- ដាក់ចេញការគ្រប់គ្រង និងយុទ្ធនាការឧទ្យានកែប និងកោះទន្សាយ គ្មានសំណល់ប្លាស្ទិកត្រឹមឆ្នាំ២០៣០។

➢ **ការអភិវឌ្ឍទេសចរណ៍ក្រុងបេតិកភណ្ឌ**

- រៀបចំយន្តការនិងផែនការសម្រាប់អភិរក្ស កែលម្អសោភណភាព និងអភិវឌ្ឍសំណង់បេតិកភណ្ឌក្នុងទីក្រុងកែប ដូចជា ព្រះរាជដំណាក់នៅពយដំណាក់ស្តេច ព្រះរាជដំណាក់

ព្រះមហាក្សត្រិយានីនារីរតន៍កុសុមៈ ផែបុរាណនៅមុខព្រះរាជដំណាក់មហាក្សត្រិយានីនារីរតន៍កុសុមៈ អតីតផ្ទះទឹមដុង និងសំណង់បេតិកភណ្ឌជាច្រើនទៀត

- សិក្សាស្រាវជ្រាវអំពីទីទួលបុរាណដ្ឋាននានាក្នុងភូមិសាស្ត្រខេត្តកែបទាំងមូល ដើម្បីគាំទ្រដល់ការរៀបចំគោលដៅទេសចរណ៍ក្រុងបេតិកភណ្ឌ និងសកម្មភាពទេសចរណ៍ប្រវត្តិសាស្ត្រនិងទេសចរណ៍វប្បធម៌។

➢ **ការអភិវឌ្ឍគោលដៅអេកូទេសចរណ៍ព្រៃកោងកាងអូរក្រសារនិងភូមិថ្មី**

- ពង្រឹងការគ្រប់គ្រងសហគមន៍ទេសចរណ៍ព្រៃកោងកាងអូរក្រសារនិងភូមិថ្មី
- ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា សម្រាប់ការអភិវឌ្ឍក្នុងសហគមន៍ទេសចរណ៍ព្រៃកោងកាងអូរក្រសារនិងភូមិថ្មី ទាំងពេលថ្ងៃនិងពេលរាត្រី ពិសេស ការចិញ្ចឹមអំពិលអំពែកឡើងវិញ ដើម្បីបង្កើតទស្សនីយភាពដ៏ទាក់ទាញនៅពេលយប់។

➢ **ការកែលម្អនិងលើកកម្ពស់ភាពទាក់ទាញទេសចរណ៍ក្រុងកែប**

- រៀបចំកែលម្អគោលដៅកម្សាន្តសំខាន់ៗ ក្នុងការត្រៀមទទួលស្វាគមន៍ភ្ញៀវទេសចរមកសម្រាកលេងកម្សាន្ត រួមមាន ១)- ការរៀបចំកែលម្អតូបកម្សាន្តនៅតាមបណ្តោយឆ្នេរនិងមុខសាលាខេត្ត (ដូចក្នុងរូបភាពទី៣ ទំព័រទី១៥) ២)- ការកែលម្អផ្សារក្តាម ផ្សារសេះស ផ្សារកែបនិងតំបន់ជុំវិញ និង៣)- ការរៀបចំកែលម្អតំបន់ឆ្នេរកែប
- ដាក់ចេញផែនការនិងយុទ្ធនាការក្រុងកែប ជាក្រុងនិរន្តរភាពអាស៊ានទាំងបីស្ងួចនាករ(ទឹកស្អាត ដីស្អាត និងខ្យល់ស្អាត)មុនឆ្នាំ២០៣០ និងជាក្រុងបេតិកភណ្ឌរបស់ UNESCO មុនឆ្នាំ២០៣៥
- ការរៀបចំសួនសាធារណៈនិងទេសភាពបៃតងសាធារណៈ (Landscape)
- កំណត់ និងរៀបចំតំបន់គ្មានយានយន្តនាចុងសប្តាហ៍ក្នុងក្រុងកែប ដោយជ្រើសយកផ្លូវ ដែលមិនប៉ះពាល់ដល់ចរាចរណ៍ឆ្លងកាត់ខេត្ត
- ពង្រឹងការត្រួតពិនិត្យស្លាកយីហោ ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រកម្ពុជានិងអត្តសញ្ញាណវប្បធម៌ជាតិ តាមរយៈការពង្រឹងការអនុវត្តលិខិតលេខ៣៣២២ ដនស/គ.អ.ធ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការប្រើប្រាស់អក្សរខ្មែរនិងអក្សរបរទេសនៅផ្ទាំងគំនូរសំណង់ឬផ្លាកសញ្ញាផ្សព្វផ្សាយនៅតាមតំបន់ឆ្នេរ
- អភិវឌ្ឍទេសចរណ៍សាសនា តាមរយៈការសិក្សានិងរៀបចំវត្តអារាមនិងទីសក្ការៈនានាក្នុងខេត្តកែបឱ្យកាន់តែមានភាពទាក់ទាញ ដូចជាមណ្ឌលសាសនានៅភ្នំសសៀរ និងមណ្ឌលសមាធិនៅវត្តសមុទ្ររង្សីជាដើម
- អភិវឌ្ឍនិងពង្រឹងការគ្រប់គ្រងឆ្នេរសាធារណៈប្រណិតកម្រិតខ្ពស់ ជាពិសេស ពិនិត្យលទ្ធភាពរៀបចំកែលម្អជាឆ្នេរកម្សាន្តនៅតាមទីតាំងសក្តានុពល រួមមានតំបន់ឆ្នេរនៅទល់មុខសាលាខេត្ត

កែប  និងនៅជិតព្រំប្រទល់ក្រុងកែបនិងស្រុកដំណាក់ចង្អើរ  សំដៅជំរុញការធ្វើពិពិធកម្មផលិតផលទេសចរណ៍ឆ្នេរខ្សាច់ឱ្យកាន់តែសម្បូរបែប

**រូបភាពទី៣: ប្លង់គោលគំនិតនៃការអភិវឌ្ឍតូបកម្សាន្តបន្សីទៅនឹងរូបរាងនៃធនធានសមុទ្រ**



### ៣.១.២- ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់អង្គោលជា "តំបន់ទេសចរណ៍ឆ្នេរសមុទ្រធម្មជាតិបែបទំនើប"

តំបន់អង្គោលសម្បូរណ៍ទៅដោយធនធានធម្មជាតិ  ដូចជាតំបន់ឆ្នេរនិងព្រៃកោងកាងប្រកបទៅដោយជីវៈចម្រុះ។ លើសពីនេះ នៅតំបន់អង្គោលមានសហគមន៍ជាច្រើន ដែលអាចត្រូវបានអភិវឌ្ឍទៅជា សហគមន៍

ទេសចរណ៍ និងមានតំបន់ស្រែអំបិលដែលអាចត្រូវបានប្រែក្លាយជាផលិតផលទេសចរណ៍ថ្មីៗ ដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែម។ ផ្អែកលើសក្តានុពលទាំងនេះ រាជរដ្ឋាភិបាលនឹងប្រែក្លាយប៉ូលទេសចរណ៍តំបន់អង្កោលជា **"តំបន់ទេសចរណ៍ឆ្នេរសមុទ្រធម្មជាតិបែបទំនើប"**។ ក្នុងន័យនេះ ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់អង្កោលនឹងត្រូវបានធ្វើឡើងតាមរយៈវិធានការ ដូចខាងក្រោម÷

➢ **ការអភិវឌ្ឍទេសចរណ៍ស្រែអំបិល**

- ជំរុញនិងគាំទ្រប្រែក្លាយតំបន់ស្រែអំបិលសក្តានុពលមួយចំនួននៅតំបន់អង្កោលនិងក្រុងកែបជាគោលដៅកសិទេសចរណ៍ស្រែអំបិល ដោយមានការរៀបចំជាសកម្មភាពផ្សេងៗ ដោយផ្តល់បទពិសោធដល់ភ្ញៀវទេសចរក្នុងការចូលរួមក្នុងសកម្មភាពផលិតកម្មអំបិល ដើម្បីជាការសិក្សាផងនិងជាសកម្មភាពកម្សាន្តផង
- ពង្រឹងសមត្ថភាពសហគមន៍ក្នុងការទទួលភ្ញៀវទេសចរ ព្រមទាំងប្រើប្រាស់បច្ចេកទេសនិងវិធីសាស្ត្រផលិតកម្មអំបិល ដែលមានភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរ ។

➢ **ការអភិវឌ្ឍទេសចរណ៍សហគមន៍តំបន់អង្កោល**

- រៀបចំបង្កើតសហគមន៍ទេសចរណ៍ភ្នំអង្កោល សម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍទេសចរណ៍សហគមន៍តំបន់អង្កោល ដោយផ្តោតលើការផ្តល់បទពិសោធជីវភាពក្នុងទីជនបទ ដល់ភ្ញៀវទេសចរ
- សិក្សានិងជំរុញការបង្កើតសកម្មភាពកម្សាន្តថ្មីៗ ដូចជាការជិះកង់កម្សាន្តក្នុងភូមិ ការជិះទូកទស្សនាព្រៃកោងកាង ជីវៈចម្រុះនិងសត្វបក្សីតាមដងព្រែកអង្កោល និងការជិះខ្សែរ៉ូកពីកំពូលភ្នំអង្កោលកាត់តាមសហគមន៍នេសាទមកកាន់ឆ្នេរអង្កោល ជាដើម
- រៀបចំកែលម្អឆ្នេរអង្កោលជាគោលដៅឆ្នេរខ្សាច់កម្សាន្ត និងលើកទឹកចិត្តដល់ការអភិវឌ្ឍរៀបចំបង្កើតទំនប់រលកឬតំបន់ការពាររលកទឹកសមុទ្រ អមដោយផែនការអភិវឌ្ឍកំពង់ផែម៉ារីណាទេសចរណ៍
- រៀបចំយុទ្ធនាការបំផុសស្មារតីរៀបចំភូមិស្អាតតាមសហគមន៍ នៅគ្រប់ទីជនបទក្នុងខេត្តកែបដោយចាប់ផ្តើមពីតំបន់ភ្នំអង្កោល ក្រោមពាក្យស្លោក**"ភូមិស្អាតកើតចេញពីប្រជាពលរដ្ឋគិត"** និង**"ភូមិស្អាត ផ្ទះស្នាក់ល្អ បង្កើនប្រាក់ចំណូល"** ដើម្បីជំរុញប្រជាជនក្នុងមូលដ្ឋានឱ្យចូលរួមក្នុងការរៀបចំភូមិទេសចរណ៍និងសហគមន៍ទេសចរណ៍ស្អាត និងការរៀបចំសេវាកម្មស្នាក់នៅតាមសហគមន៍ទូទាំងខេត្តកែបសម្រាប់ទទួលស្វាគមន៍ភ្ញៀវទេសចរ។

➢ **ការអភិវឌ្ឍទេសចរណ៍តំបន់ព្រៃកោងកាងនៅព្រំប្រទល់ក្រុងកែបនិងស្រុកដំណាក់ចង្អើរ**

- រៀបចំផែនការអភិវឌ្ឍតំបន់អេកូទេសចរណ៍ព្រៃកោងកាងកែប-អង្កោល ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវ និងមានការចូលរួមពីសំណាក់ប្រជាជន ម្ចាស់ដី និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីធានាចីរភាពនៃការអភិវឌ្ឍអេកូទេសចរណ៍ក្នុងតំបន់នេះ។

### ៣.១.៣- ការអភិវឌ្ឍប៉ូលទេសចរណ៍ធម្មជាតិតំបន់ភ្នំវល្លិ៍ជា "តំបន់កសិទេសចរណ៍និងទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ"

តំបន់ភ្នំវល្លិ៍មានសក្តានុពលជាគោលដៅទេសចរណ៍តំបន់ភ្នំ ដែលមានប្រវត្តិជាអតីតមូលដ្ឋានទ័ពរបស់ខ្មែរក្រហម និងជាតំបន់កសិកម្មដ៏សំខាន់របស់ខេត្តកែប ដែលសម្បូណ៌ទៅដោយចំការម្រេចនិងដំណាំគួបផ្សំជាច្រើនទៀត។ ផ្អែកលើសក្តានុពលទាំងនេះ រាជរដ្ឋាភិបាលនឹងប្រែក្លាយប៉ូលទេសចរណ៍ធម្មជាតិតំបន់ភ្នំវល្លិ៍ជា**"តំបន់កសិទេសចរណ៍និងទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ"**។ ក្នុងន័យនេះ ការអភិវឌ្ឍប៉ូលទេសចរណ៍ធម្មជាតិតំបន់ភ្នំវល្លិ៍ នឹងត្រូវធ្វើឡើងតាមរយៈការអនុវត្តវិធានការ ដូចខាងក្រោម÷

➢ **ការអភិវឌ្ឍកសិទេសចរណ៍តំបន់ភ្នំវល្លិ៍**

- អភិវឌ្ឍកសិទេសចរណ៍តំបន់ភ្នំវល្លិ៍ ដោយធ្វើការសិក្សា និងរៀបចំចងក្រងទីតាំងដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យកសិទេសចរណ៍ ជាពិសេសនៅតំបន់ចំការម្រេច និងចំការទុរេន ដោយមានកិច្ចសហការឱ្យបានជិតស្និតជាមួយម្ចាស់ចំការ និងប្រជាជនក្នុងមូលដ្ឋាន ដើម្បីរៀបចំសម្បទាទេសចរណ៍ចាំបាច់នានា និងកំណត់ប្រភេទសេវាកម្ម និងផលិតផលទេសចរណ៍ដែលមាននៅតាមទីតាំងនីមួយៗ។
- បង្កើនផលិតភាព និងធ្វើពិពិធកម្មផលិតផលកសិកម្មក្នុងខេត្តកែប សំដៅធានានូវការផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងស្រុកក្នុងកម្រិតអតិបរមា ដល់ភ្ញៀវទេសចរ ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តកែបទាំងមូល។
- ពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើតផ្សារផលិតផលកសិកម្មសម្បូណ៌បែប សំដៅទាក់ទាញភ្ញៀវទេសចរ និងផ្សព្វផ្សាយនូវផលិតផលកសិកម្ម និងកសិឧស្សាហកម្ម ជាពិសេសផលិតផលដែលមានសក្តានុពលក្នុងខេត្តកែប។

➢ **ការអភិវឌ្ឍទេសចរណ៍ប្រវត្តិសាស្ត្រសង្គ្រាម និងទេសចរណ៍ផ្សងព្រេងតំបន់ភ្នំវល្លិ៍**

- អភិវឌ្ឍទេសចរណ៍ប្រវត្តិសាស្ត្រសង្គ្រាមតំបន់ភ្នំវល្លិ៍ ដោយធ្វើការសិក្សាស្រាវជ្រាវលម្អិតអំពីប្រវត្តិសាស្ត្រសង្គ្រាម គួបផ្សំជាមួយនឹងការប្រមូលនូវវត្ថុបុរាណ ដូចជាគ្រឿងយុទ្ធភ័ណ្ឌ និងគ្រឿងសព្វាវុធចាស់ៗ និងរៀបចំបង្កើតភូមិទេសចរណ៍ប្រវត្តិសាស្ត្រ ក្នុងភូមិចំការបីនៃស្រុកដំណាក់ចង្អើរ។
- អភិវឌ្ឍទេសចរណ៍ផ្សងព្រេងតំបន់ភ្នំវល្លិ៍ ដោយពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើនៅក្នុងតំបន់ភ្នំវល្លិ៍ និងសិក្សា កំណត់តំបន់ និងផ្លូវខ្សែទស្សនកិច្ចទេសចរណ៍សម្រាប់សកម្មភាពផ្សងព្រេងកម្សាន្តក្នុងព្រៃ និងរៀបចំបង្កើតសម្បទាទ្រទ្រង់ការធ្វើពិពិធកម្មផលិតផលទេសចរណ៍កម្សាន្តក្នុងព្រៃឱ្យកាន់តែសម្បូណ៌បែប ។

### ៣.១.៤- ការអភិវឌ្ឍប៉ូលទេសចរណ៍សមុទ្រនិងតំបន់ប្រជុំកោះជា "តំបន់ទេសចរណ៍សមុទ្រកោះប្រណិត"

សមុទ្រនិងតំបន់ប្រជុំកោះនៃខេត្តកែប ជាគោលដៅទេសចរណ៍ដែលមានធនធានធម្មជាតិ សម្បូណ៌ទៅដោយធនធានជីវៈចម្រុះបាតសមុទ្រនិងផ្កាថ្មដ៏ស្រស់ស្អាតចម្រុះពណ៌ ដែលអាចត្រូវបានអភិវឌ្ឍជាប៉ូលទេសចរណ៍តំបន់កោះយ៉ាងសំខាន់។ ផ្អែកលើសក្ដានុពលទាំងនេះ រាជរដ្ឋាភិបាលនឹងប្រែក្លាយប៉ូលទេសចរណ៍សមុទ្រនិងតំបន់ប្រជុំកោះជា"**តំបន់ទេសចរណ៍សមុទ្រកោះប្រណិត**"។ ក្នុងន័យនេះ ការអភិវឌ្ឍប៉ូលទេសចរណ៍សមុទ្រនិងតំបន់ប្រជុំកោះ នឹងត្រូវធ្វើឡើងតាមរយៈការអនុវត្តវិធានការ ដូចខាងក្រោម÷

- **ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍កោះបែបប្រណិត**
  - សិក្សា កំណត់ និងអនុវត្តស្តង់ដាមួយច្បាស់លាស់ សម្រាប់សកម្មភាពអាជីវកម្មនិងគម្រោងវិនិយោគលើសេវាកម្មទេសចរណ៍សំខាន់ៗ ដូចជាសណ្ឋាគារឬរមណីយដ្ឋាននានាក្នុងតំបន់កោះ ដើម្បីធានាគុណភាពនិងការអភិវឌ្ឍប្រកបដោយចីរភាព
  - ជំរុញការថែរក្សានិងការអភិរក្សតំបន់ឆ្នេរនិងធនធានធម្មជាតិសំខាន់ៗនៅលើកោះ ដោយមានការកំណត់យន្តការនិងស្ថាប័នទទួលខុសត្រូវច្បាស់លាស់
  - កំណត់និងបង្កើតតំបន់ប្រជុំកោះនានាជាឧទ្យានជាតិសមុទ្រ និងដាក់បញ្ចូលជាឧទ្យានបេតិក-ភណ្ឌអាស៊ាន (ASEAN Heritage Park) ត្រឹមឆ្នាំ២០៣០
  - បន្តជំរុញដាក់បញ្ចូលទាំងឧទ្យានជាតិកែប តំបន់ក្រុងកែបចាស់ និងឧទ្យានជាតិសមុទ្រខាងលើ និងតំបន់ជីវចម្រុះព្រែកចាកទៅក្នុង (UNESCO Biosphere Reserve) នៅឆ្នាំ២០៣៥
- **ការកសាងមូលដ្ឋានសម្រាប់អភិវឌ្ឍសកម្មភាពទេសចរណ៍លើផ្ទៃសមុទ្រ និងក្រោមសមុទ្រ**
  - សិក្សានិងរៀបចំធ្វើការបែងចែកតំបន់ និងកំណត់ទីតាំងនិងអត្តសញ្ញាណធនធានធម្មជាតិនិងជីវៈចម្រុះ នៅលើកោះនិងក្នុងសមុទ្រនៃខេត្តកែប សម្រាប់ជាមូលដ្ឋានក្នុងការអភិរក្សផង និងការរៀបចំបង្កើតផលិតផល ឬសកម្មភាពទេសចរណ៍លើផ្ទៃសមុទ្រនិងក្រោមសមុទ្រផង។

### ៣.១.៥- យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍតំបន់ប៉ូលទេសចរណ៍

ការអភិវឌ្ឍតំបន់ប៉ូលទេសចរណ៍នីមួយៗ ទាមទារឱ្យមានការចូលរួមសហការពីភាគីពាក់ព័ន្ធជាច្រើន ដើម្បីធានាការអភិវឌ្ឍអាចប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់។ ក្នុងស្មារតីនេះ ដើម្បីគាំទ្រដល់ការអភិវឌ្ឍតំបន់ប៉ូលទេសចរណ៍នីមួយៗ រាជរដ្ឋាភិបាលបានកំណត់វិធានការ ដូចខាងក្រោម÷

- ដោយមានការគាំទ្រពីគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ គណៈកម្មការអភិវឌ្ឍន៍ទេស-ចរណ៍ខេត្តកែប សហការជាមួយនឹងវិស័យឯកជន ព្រមទាំងសហគមន៍ក្នុងមូលដ្ឋានពាក់ព័ន្ធនឹងវិស័យទេសចរណ៍ដើម្បីធ្វើការរួមគ្នាអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប និងទទួលខុសត្រូវ

ក្នុងការអភិរក្ស ព្រមទាំងរៀបចំផែនការអភិវឌ្ឍគោលដៅទេសចរណ៍និងពង្រឹងប្រសិទ្ធភាពការងារនៅតាមគោលដៅកម្សាន្តក្នុងប៉ូលទេសចរណ៍នីមួយៗ

- ពង្រឹងសមត្ថភាពវិស័យឯកជន សមាគម និងសហគមន៍តាមតំបន់ប៉ូលទេសចរណ៍នីមួយៗក្នុងការធានាប្រសិទ្ធភាពនិងនិរន្តរភាពក្នុងការគ្រប់គ្រងគោលដៅទេសចរណ៍នីមួយៗ
- បំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សំដៅបង្កើនប្រសិទ្ធភាពការងារ ការតភ្ជាប់ជាមួយភាគីពាក់ព័ន្ធ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅកាន់ទីផ្សារជាតិនិងអន្តរជាតិ និងជាពិសេសប្រែក្លាយប៉ូលទេសចរណ៍នីមួយៗឱ្យក្លាយជាប៉ូលទេសចរណ៍ឆ្លាតវៃ
- រៀបចំយន្តការការផ្សព្វផ្សាយ និងប្រឹក្សាយោបល់ឱ្យបានទូលំទូលាយ សំដៅគាំទ្រដល់ការលូតលាស់នៃវិស័យឯកជន សហគមន៍ទេសចរណ៍ សមាគមទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍ជាតិ និងអន្តរជាតិ។

### ៣.១.៦- ការអភិវឌ្ឍផលិតផលនិងព្រឹត្តិការណ៍ទេសចរណ៍ផ្សេងៗក្នុងខេត្តកែប

ដើម្បីបង្កើតជាផលិតផលទេសចរណ៍ថ្មីឱ្យកាន់តែច្រើន ដែលអាចចូលរួមគាំទ្រដល់ការទាក់ទាញភ្ញៀវទេសចរបន្ថែម និងជំរុញឱ្យមានសកម្មភាពកម្សាន្តដ៏ទាក់ទាញ រស់រវើក និងប្លែកៗពីគ្នាក្នុងគ្រប់រដូវកាល ខេត្តកែបអាចទទួលបានផលប្រយោជន៍បន្ថែមទៀតពីការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗជាប្រចាំ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការ ដូចខាងក្រោម÷

- រៀបចំបង្កើតព្រឹត្តិការណ៍ទេសចរណ៍ប្រចាំឆ្នាំថ្មីៗ ដូចជាៈ ពិធីបុណ្យក្ដាមសមុទ្រ ពិធីបុណ្យតួរ្យតន្ត្រី ពិធីបុណ្យពន្លឺប្រចាំឆ្នាំ វិថីម្ហូបអាហារខេត្តកែប និងការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាទេសចរណ៍លើទឹកប្រចាំឆ្នាំ ជាដើម
- អភិវឌ្ឍនិងពង្រឹងរបៀងទេសចរណ៍អាហារសមុទ្រខេត្តកែប តាមរយៈការបន្តពង្រឹងគុណភាពម្ហូបអាហារនៅតាមភោជនីយដ្ឋាន និងការផ្គត់ផ្គង់ផលិតផលម្ហូបអាហារនានា
- សិក្សានិងកំណត់ទីតាំងមួយចំនួននៅក្នុងក្រុងកែបសម្រាប់បង្កើតជាផ្សាររាត្រីដែលមានតាំងលក់ផលិតផលចម្រុះក្នុងស្រុក ដូចជាកសិផល សិប្បកម្មគ្រឿងសមុទ្រ ជាពិសេសមុខម្ហូបនិងអាហារសមុទ្រធម្មជាតិដ៏សម្បូរបែប សំដៅបង្កើនសកម្មភាពកម្សាន្តនាពេលយប់ និងពង្រឹងអត្តសញ្ញាណផលិតផលម្ហូបអាហារខេត្តកែប
- ជំរុញការបំផុសចលនាមកកម្សាន្តខេត្តកែប តាមរយៈយុទ្ធនាការ **"ខ្ញុំស្រលាញ់ខេត្តកែប"** និង/ឬអាចបង្កើតពិធីបុណ្យជាផ្លូវការហៅថាបុណ្យ **"ខ្ញុំស្រលាញ់ខេត្តកែបៈ I LOVE KEP DAY"** ដើម្បីគាំទ្រដល់ការផ្សព្វផ្សាយនិងបង្កើនទំហំទីផ្សារទេសចរណ៍មកកាន់ខេត្តកែប។

### ៣.១.៧- ការអភិវឌ្ឍខេត្តកែប-កំពតជាគោលដៅទេសចរណ៍រួម

ផ្អែកលើក្របខ័ណ្ឌប្រវត្តិសាស្ត្រនិងទីតាំងភូមិសាស្ត្រ ខេត្តកែបនិងខេត្តកំពតត្រូវបានចាត់ទុកជាគោលដៅតែមួយ។ បន្ថែមពីនេះ ខេត្តទាំងពីរមានភូមិសាស្ត្រជាប់គ្នានិងមានសក្តានុពលធនធានធម្មជាតិប្រហាក់ប្រហែលគ្នា ហើយការអភិវឌ្ឍទេសចរណ៍នៃខេត្តទាំងពីរមានលក្ខណៈបំពេញបន្ថែម និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ ក្នុងន័យនេះ ដើម្បីពង្រីកវិសាលភាពនិងទាញយកប្រយោជន៍ពីសហថាមភាពនៃខេត្តកែបនិងខេត្តកំពត ជាគោលដៅទេសចរណ៍រួមមួយ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការដូចខាងក្រោម÷

- អភិវឌ្ឍគោលដៅកម្សាន្តតំបន់ព្រៃកោងកាងព្រែកអង្កោលនិងព្រែកចាករួមគ្នា តាមរយៈការជំរុញនិងពន្លឿនការរៀបចំ និងដាក់អនុម័តឱ្យប្រើប្រាស់ផែនការប្រើប្រាស់ដីតំបន់ព្រៃកោងកាងអង្កោលនិងព្រែកចាក ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការមេគ្រប់គ្រងនិងអភិរក្ស សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យអេកូទេសចរណ៍ក្នុងតំបន់
- ពង្រឹងសហគមន៍អេកូទេសចរណ៍តំបន់ព្រៃកោងកាងអង្កោល-ព្រែកចាក ក្នុងការការចូលរួមថែរក្សាព្រៃកោងកាងនិងអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ដើម្បីទាញយកផលប្រយោជន៍ពីទេសចរណ៍ក្នុងតំបន់នេះ
- ពង្រឹងការអភិវឌ្ឍនិងផ្សព្វផ្សាយទេសចរណ៍រួមគ្នា តាមរយៈការរៀបចំនូវព្រឹត្តិការណ៍ទេស-ចរណ៍ ព្រឹត្តិការណ៍កីឡា ព្រឹត្តិការណ៍វិនិយោគ និងពិធីបុណ្យរួមគ្នា ដូចជាពិធីបុណ្យព្រៃកោងកាងនិងពិធីបុណ្យម្រេច ជាដើម
- សិក្សានិងពិនិត្យលទ្ធភាពបង្កើតរថយន្តក្រុង ខ្សែរថភ្លើង (Tramways) និងទូកទេសចរណ៍តភ្ជាប់រវាងខេត្តកែបនិងកំពត ដើម្បីសម្រួលនិងកាត់បន្ថយចំណាយនៃការធ្វើដំណើរដល់ភ្ញៀវទេសចរនិងប្រជាពលរដ្ឋ។

## ៣.២- យុទ្ធសាស្ត្រលើកកម្ពស់ការវិនិយោគ អភិវឌ្ឍធនធានមនុស្ស និងផ្សព្វផ្សាយទីផ្សារ

ការអភិវឌ្ឍវិស័យទេសចរណ៍ ទាមទារឱ្យមានការវិនិយោគពីសំណាក់វិស័យឯកជន មានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ទ្រទ្រង់វិស័យទាំងមូល និងមានការផ្សព្វផ្សាយទីផ្សារ ដើម្បីទាក់ទាញភ្ញៀវទេសចរនិងវិនិយោគិន។ ក្នុងន័យនេះ ការដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការវិនិយោគ អភិវឌ្ឍធនធានមនុស្សនិងផ្សព្វផ្សាយទីផ្សារ គឺជាកិច្ចការចាំបាច់។

### ៣.២.១- ការលើកកម្ពស់វិនិយោគនិងអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប ជាគោលដៅទេសចរណ៍សម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់ អាស្រ័យលើការជំរុញការវិនិយោគបែបគុណភាពឱ្យមានចលនាកាន់តែមានភាពរស់រវើក ដើម្បីឱ្យមាននូវ

ផលិតផលទេសចរណ៍និងសេវាកម្មទេសចរណ៍ កាន់តែសម្បូណ៌បែប ប្រកបដោយគុណភាព សុវត្ថិភាព និងភាពទាក់ទាញសម្រាប់ទទួលភ្ញៀវទេសចរ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ ដូចខាងក្រោម÷

➢ **ការលើកកម្ពស់វិនិយោគទេសចរណ៍**

- សិក្សានិងកំណត់ទីតាំងដែលមានសក្តានុពល សម្រាប់គម្រោងវិនិយោគអាទិភាព ជាពិសេសនៅតាមបណ្តាទីតាំងរបស់រដ្ឋ ដើម្បីត្រៀមខ្លួនសហការជាមួយវិស័យឯកជនក្នុងការអភិវឌ្ឍគោលដៅទាំងនោះ
- រៀបចំវេទិកាវិនិយោគទេសចរណ៍ខេត្តកែបប្រចាំឆ្នាំ ដើម្បីជំរុញនិងទាក់ទាញការវិនិយោគពីវិនិយោគិននៅក្នុងស្រុក និងការវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងផ្សះផ្សងរវាងវិនិយោគិននិងសហគ្រិន
- សិក្សានិងកំណត់ទីតាំងសមស្រប ដើម្បីរៀបចំបង្កើតជាភូមិគ្រឹះឆ្នេរសមុទ្រកែប ក្នុងគោលបំណងបង្កើតសារមន្ទីរសមុទ្រ ដែលនឹងក្លាយជាមណ្ឌលរក្សាឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រ សម្រាប់ទទួលភ្ញៀវទេសចរ និងអ្នកសិក្សាស្រាវជ្រាវមកពីគ្រប់មជ្ឈដ្ឋាន ពិសេសវិនិយោគិនដែលមានបំណងស្វែងយល់ពីសក្តានុពលនិងឱកាសវិនិយោគក្នុងខេត្តកែប
- សិក្សានិងរៀបចំយន្តការជំរុញការវិនិយោគទេសចរណ៍ផ្ទះទី២ ដើម្បីទាក់ទាញភ្ញៀវទេសចរសុខភាព ស្រលាញ់ធម្មជាតិ និងភាពស្ងប់ស្ងាត់ រួមទាំងទេសចរណ៍វ័យចំណាស់ មកកម្សាន្តនិងស្នាក់នៅសម្រាប់រយៈពេលយូរនៅក្នុងខេត្តកែប
- ពង្រឹងការអនុវត្តវិធានការសារពើពន្ធដែលមានជាធរមាន ដើម្បីជំរុញនិងលើកទឹកចិត្តឱ្យមានការថែទាំនិងប្រើប្រាស់ដី។

➢ **ជំរុញការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ខេត្តកែប**

- រៀបចំកម្មវិធីបណ្តុះបណ្តាល សំដៅពង្រឹងគុណភាពសមត្ថភាពរបស់បុគ្គលិកតាមជំនាញដោយផ្តោតទាំងការបណ្តុះបណ្តាលមូលដ្ឋាន និងការបណ្តុះបណ្តាលវិក្រឹតការ
- ជំរុញការបើកវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ផ្ទៃកខាងក្នុង (In-house Training) ជាប្រចាំទៅតាមប៉ូលទេសចរណ៍នីមួយៗ សំដៅពង្រឹងគុណភាពសមត្ថភាពរបស់បុគ្គលិកតាមជំនាញ។

### ៣.២.២- យុទ្ធសាស្ត្រទីផ្សារនិងផ្សព្វផ្សាយ

ដើម្បីគាំទ្រនិងជំរុញកំណើនទាំងការវិនិយោគ និងទាក់ទាញភ្ញៀវទេសចរគុណភាពមកខេត្តកែបកាន់តែច្រើននិងស្នាក់នៅកាន់តែយូរ ការដាក់ចេញយុទ្ធសាស្ត្រទីផ្សារនិងផ្សព្វផ្សាយពង្រឹងគោលដៅពិតជាមានសារៈសំខាន់ទាំងរយៈពេលខ្លី និងរយៈពេលវែង។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដូចខាងក្រោម÷

- **ការអភិវឌ្ឍកិត្តិនាមនិងម៉ាកគោលដៅទេសចរណ៍ខេត្តកែប**
  - ជំរុញការបង្កើតកិត្តិនាមនិងម៉ាកគោលដៅទេសចរណ៍ខេត្តកែប ជាគោលដៅទេសចរណ៍ធម្មជាតិ សុខភាពនិងប្រណិត និងផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ
  - ជំរុញនិងរៀបចំខេត្តកែបជាគោលដៅទេសចរណ៍ស្ទូឌីយ៉ូធម្មជាតិ សម្រាប់ការថតភាពយន្ត ល្បែងផ្សងព្រេង និងកម្មវិធីអាពាហ៍ពិពាហ៍ជាដើម។
- **ការពង្រឹងយន្តការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ខេត្តកែប**
  - ពង្រឹងការគ្រប់គ្រងនិងរៀបចំឱ្យមានមណ្ឌលព័ត៌មានទេសចរណ៍ នៅតាមគោលដៅទេសចរណ៍សំខាន់ៗ ដែលអាចផ្តល់ព័ត៌មានពាក់ព័ន្ធនឹងគោលដៅកម្សាន្ត ការស្នាក់នៅ ម្ហូបអាហារ អាកាសធាតុ និងសេវាកម្មទេសចរណ៍ផ្សេងៗ
  - បង្កើតថ្នាលបច្ចេកវិទ្យានានា សម្រាប់បណ្តាញប្រតិបត្តិករទេសចរណ៍ជាតិនិងអន្តរជាតិ ជាពិសេសអង្គភាពគ្រប់គ្រងគោលដៅក្នុងប៉ូលទេសចរណ៍នីមួយៗ ដើម្បីជាមូលដ្ឋានក្នុងការផ្សព្វ-ផ្សាយគោលដៅទេសចរណ៍ខេត្តកែប ឱ្យបានកាន់តែទូលំទូលាយក្នុងទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ
  - ជំរុញការផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តកែបទៅកាន់ទីផ្សារទេសចរណ៍អន្តរជាតិ តាមរយៈយន្តការផ្សព្វផ្សាយនានា ដូចជា: **១)**- យន្តការផ្សព្វផ្សាយតាមរយៈក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក **២)**- បង្កើនការចូលរួមព្រឹត្តិការណ៍ពិព័រណ៍ទេសចរណ៍អន្តរជាតិសំខាន់ៗ និង**៣)**- សហការជាមួយអ្នកមានឥទ្ធិពលក្នុងបណ្តាញសង្គម ដូចជា YouTube និង Instagram ជាដើម
  - បង្កើតឱ្យមានទូតសុឆន្ទៈតំណាងខេត្តកែបទៅតាមវិស័យ ដូចជាៈ វិស័យទេសចរណ៍ វិស័យបរិស្ថាននិងធនធានធម្មជាតិ និងអាហារសមុទ្រ ជាដើម ដើម្បីជំរុញការផ្សព្វផ្សាយសក្តានុពលទេសចរណ៍សំខាន់ៗនៅក្នុងខេត្តកែប។

### ៣.៣- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ខេត្តកែប

ការអភិវឌ្ឍតំបន់ទេសចរណ៍ដ៏ទាក់ទាញ ប្រកបដោយគុណភាព និងសម្បូរបែប ត្រូវពឹងផ្អែកទៅលើការអភិវឌ្ឍវិស័យគាំទ្រចម្បងៗមួយចំនួន ដូចជា ការគ្រប់គ្រងសន្តិសុខ ការគ្រប់គ្រងសំណល់ សោភណភាព និងរចនាបថសំណង់ ហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹកស្អាត ការអភិវឌ្ឍវិស័យកសិកម្ម ការគ្រប់គ្រងគ្រោះមហន្តរាយ និងការធ្វើទំនើបកម្មវិស័យសុខាភិបាលជាដើម។ ក្នុងន័យនេះ ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែបប្រកបដោយប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវមានការបំពេញបន្ថែមដោយការដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍អន្តរវិស័យគាំទ្រសំខាន់ៗ ដូចខាងក្រោម ÷

### ៣.៣.១- យុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍន៍អន្តរវិស័យគាំទ្រ

ដើម្បីជំរុញដល់ការគ្រប់គ្រងនិងការអភិវឌ្ឍអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប យុទ្ធសាស្ត្រមួយចំនួនត្រូវបានដាក់ចេញ ទៅតាមវិស័យនិងទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម÷

➢ **ការពង្រឹងសន្តិសុខ**

- ធ្វើទំនើបកម្មប្រព័ន្ធសន្តិសុខ ដោយបំពាក់ប្រព័ន្ធបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសន្តិសុខនិងសុវត្ថិភាពនៅក្នុងខេត្តកែប
- បន្ថែមការបំពាក់ភ្លើងបំភ្លឺសាធារណៈនាពេលរាត្រី នៅតាមគោលដៅកម្សាន្តចម្បងៗ
- បង្កើនចំនួននិងពង្រឹងគុណភាពនៃកងកម្លាំងនគរបាលទេសចរណ៍ ដើម្បីចូលរួមធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៅក្នុងខេត្តកែប ជាពិសេសនៅតាមតំបន់ប៉ូលទេសចរណ៍ទាំងបួន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីត្រៀមខ្លួនសម្រាប់ទទួលការកើនឡើងនៃភ្ញៀវទេសចរ
- បន្តពង្រឹងការអនុវត្តគោលនយោបាយ"**ភូមិ ឃុំសង្កាត់ មានសុវត្ថិភាព**" ឱ្យបានម៉ឺងម៉ាត់នៅតាមមូលដ្ឋានភូមិ ឃុំ និងសង្កាត់នីមួយៗ ដើម្បីលើកកម្ពស់សុវត្ថិភាពជារួមនៅក្នុងខេត្តកែប ឆ្លើយតបទៅនឹងតម្រូវការការពារសន្តិសុខនិងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិនិងអន្តរជាតិ។
- រៀបចំឱ្យមានឆ្មាំសមុទ្រប្រចាំការនៅគ្រប់គោលដៅរមណីយដ្ឋានឆ្នេរសមុទ្រ ទាំងនៅលើដីគោក និងនៅតាមបណ្តាកោះក្នុងភូមិសាស្ត្រខេត្តកែប ដើម្បីចូលរួមថែរក្សានិងការពារសុវត្ថិភាពជូនភ្ញៀវទេសចរ ស្របតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៧៥.សសរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមឆ្មាំសមុទ្រកម្ពុជា។

➢ **ការពង្រឹងវិស័យសុខាភិបាល**

- ធ្វើទំនើបកម្មមន្ទីរពេទ្យបង្អែកខេត្តកែបពីកម្រិត១ ទៅកម្រិត២ ត្រឹមឆ្នាំ២០២៦ និងទៅកម្រិត ៣ ត្រឹមដំណាច់ឆ្នាំ២០៣០
- បន្តពង្រឹងការអនុវត្តវិធានសុខាភិបាល វិធានសុវត្ថិភាពទេសចរណ៍និងវិធានការនានា ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងរាតត្បាតនៃជំងឺឆ្លង នៅតាមគោលដៅទេសចរណ៍នៅក្នុងខេត្តកែប
- ជំរុញនិងលើកទឹកចិត្តដល់វិស័យឯកជនធ្វើការសិក្សាលទ្ធភាពវិនិយោគលើការបង្កើតមន្ទីរពេទ្យវេជ្ជសាស្ត្រពហុព្យាបាលឯកជននិងគ្លីនិកកម្រិតខ្ពស់ ដែលមានមធ្យោបាយដឹកជញ្ជូនសង្គ្រោះបន្ទាន់ទំនើបៗគ្រប់គ្រាន់ ដូចជារថយន្តសង្គ្រោះបន្ទាន់ ទូកល្បឿនលឿន និងឧទ្ធម្ភាគចក្រជាដើម។

➢ **ការពង្រឹងការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ**

- រៀបចំផែនការគ្រប់គ្រងសំណល់រឹងនិងសំណល់រាវ ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងរក្សាឧត្តមភាពខេត្តកែបជាគោលដៅទេសចរណ៍ធម្មជាតិបែបប្រណីតកម្រិតខ្ពស់មានទឹកស្អាត ដីស្អាត និងខ្យល់ស្អាត

- ពង្រឹងនិងពង្រីកសមត្ថភាពនៃការគ្រប់គ្រងសំណល់រឹង ជាពិសេសជំរុញការពង្រីកប្រតិបត្តិការនៃសេវាប្រមូលសំរាមសំណល់រឹងឱ្យបានគ្រប់ទីកន្លែង និងទុកដាក់សំរាមសំណល់រឹងឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់
- អនុវត្តកម្មវិធីញែកសំណល់រឹង ចាប់ពីដើមខ្សែដល់ចុងខ្សែ
- រៀបចំយន្តការជំរុញការអភិវឌ្ឍខេត្តកែប ជាគោលដៅអេកូទេសចរណ៍គ្មានសំណល់ប្លាស្ទិក
- បង្កើនការស្ថាបនាអាងប្រព្រឹត្តកម្មសំណល់រាវឱ្យបានគ្រប់គ្រាន់ និងពង្រឹងការគ្រប់គ្រងសំណល់រាវនៅតាមមូលដ្ឋានអាជីវកម្ម ក៏ដូចជានៅតាមលំនៅឋាន
- ត្រួតពិនិត្យ និងតាមដានគុណភាពទឹកសមុទ្រក្នុងរយៈពេល ៣ខែម្តង នៅតាមទីតាំងមួយចំនួនដូចជា ក្នុងតំបន់ផ្សារក្តាម ឆ្នេរកែប ឆ្នេរអង្កោល និងឆ្នេរសហគមន៍កោះទន្សាយ ព្រមទាំងទីតាំងសក្តានុពលទេសចរណ៍ផ្សេងៗទៀត
- លើកកម្ពស់ការអប់រំ ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងទៅដល់សាធារណជនអំពីការការពារបរិស្ថាននិងអនាម័យ ជាពិសេសការគ្រប់គ្រង និងទុកដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ។

➢ **ការពង្រឹងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បន្តអនុវត្តការប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកែបចក្ខុវិស័យឆ្នាំ២០៣០ ស្របតាមសេចក្តីសម្រេចលេខ០០១ សសរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីផែនទីប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ២០៣០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ពន្លឿនការរៀបចំនិងអនុម័តប្លង់គោលប្រើប្រាស់ដីស្រុកដំណាក់ចង្អើរ ដែលនឹងបញ្ជាក់ពីទិសដៅនៃការអភិវឌ្ឍស្រុកទាំងមូល ដែលនឹងដើរតួជាផែនទីចង្អុលផ្លូវយ៉ាងសំខាន់ គាំទ្រដល់ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់អង្កោលនិងប៉ូលទេសចរណ៍តំបន់ភ្នំវល្លិ៍ ប្រកបដោយចីរភាពទាំងលើទិដ្ឋភាពសង្គម ទេសចរណ៍ បរិស្ថាន និងការរៀបចំដែនដីនិងនគរូបនីយកម្ម
- សិក្សានិងកំណត់អត្តសញ្ញាណរចនាបថសំណង់និងនគរូបនីយកម្មសម្រាប់ប៉ូលអភិវឌ្ឍនីមួយៗនៃខេត្តកែប ឱ្យមានស្តង់ដារួមមួយច្បាស់លាស់ ឈរលើទិដ្ឋភាពវប្បធម៌ និងធម្មជាតិ
- លើកកម្ពស់នវានុវត្តភាពនៃរចនាបថសំណង់ ស្របតាមអត្តសញ្ញាណនគរូបនីយកម្មដែលបានកំណត់តាមតំបន់ប៉ូលទេសចរណ៍នីមួយៗ
- កំណត់តំបន់សម្រាប់សាងសង់ច្រកចូលនិងចេញខេត្តកែប ក្រុងកែប និងស្រុកដំណាក់ចង្អើរ។

➢ **ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍**

- ស្ថាបនានិងពង្រីកផ្លូវតភ្ជាប់តំបន់ទេសចរណ៍សំខាន់ៗ ជាពិសេសក្នុងស្រុកដំណាក់ចង្អើរដែលត្រូវធ្វើការរៀបចំកែលម្អ
- កែលម្អនិងអភិវឌ្ឍប្រព័ន្ធលូសាធារណៈឱ្យបានត្រឹមត្រូវ ដោយគិតគូរបំបែកចែករវាងលូទឹកភ្លៀង និងលូទឹកសម្អុយ ដើម្បីធានាដល់ការគ្រប់គ្រងជំនន់ទឹកភ្លៀងនិងសំណល់ទឹកកខ្វក់

- ពង្រឹងកិច្ចសហការឱ្យបានខ្ជាប់ខ្ជួនរវាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការស្ថាបនាផ្លូវគមនាគមន៍ និងការរៀបចំអភិវឌ្ឍប្រព័ន្ធលូសាធារណៈ
- សិក្សាកំណត់មុខងារផ្លូវឱ្យបានច្បាស់លាស់សម្រាប់រថយន្ត ផ្លូវទោចក្រយានយន្ត ផ្លូវទោចក្រយាន និងផ្លូវថ្មើរជើង ដើម្បីកែលម្អផ្លូវគមនាគមន៍ជាផ្លូវទេសចរណ៍ដ៏មានសោភ័ណភាព ក៏ដូចជាបម្រើឱ្យប្រពលរដ្ឋអាចប្រើប្រាស់ស្របតាមតម្រូវការ ប្រកបដោយសុវត្ថិភាព
- សិក្សានិងពិនិត្យលទ្ធភាពសាងសង់ចំណតយានយន្តសាធារណៈ ដូចជានៅតំបន់ផ្សារក្តាម តំបន់ឆ្នេរកែប តំបន់មុខសាលាខេត្តកែប និងតំបន់ឆ្នេរអង្កោល ព្រមទាំងតំបន់ផ្សេងទៀតដែលជាទីប្រជុំជននិងកន្លែងកម្សាន្តសំខាន់ៗ
- សិក្សានិងកំណត់តំបន់សម្រាប់សាងសង់កំពង់ផែម៉ារីណាទេសចរណ៍ ដើម្បីចូលរួមគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍កីឡាលើទឹក និងជំរុញឱ្យមានការប្រើប្រាស់ទូកកម្សាន្តនៅតាមសមុទ្រស្របតាមតម្រូវការទីផ្សារទេសចរណ៍កម្រិតខ្ពស់។

➢ **វិស័យកសិកម្ម**

- ពង្រឹងការគ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម តាមរយៈការពង្រឹងការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងក្នុងការការពារធនធានធម្មជាតិ ដោយតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន សហគមន៍និងប្រជាពលរដ្ឋ សហការការពារព្រៃកោងកាង តំបន់អភិរក្សផ្កាថ្មស្មៅសមុទ្រ និងធនធានជលផល
- សិក្សានិងស្វែងរកកិច្ចសហការ ជួយគាំទ្រទាំងមធ្យោបាយ សម្ភារៈ និងបច្ចេកទេស ដល់សហគមន៍នេសាទដែលមានស្រាប់ ដូចជាសហគមន៍នេសាទអូរក្រសារ សហគមន៍នេសាទភូមិថ្មី សហគមន៍នេសាទអង្កោល សហគមន៍នេសាទភូមិកំពង់ត្រឡាច សហគមន៍នេសាទភូមិកែប និងសហគមន៍នេសាទដែលនឹងត្រូវបង្កើតផ្សេងទៀត។

➢ **ការពង្រឹងការផ្គត់ផ្គង់ថាមពលអគ្គិសនី**

- រៀបចំគោលការណ៍ណែនាំ និងលើកទឹកចិត្តក្នុងការប្រើប្រាស់ថាមពលកកើតឡើងវិញដល់គ្រប់មូលដ្ឋានអាជីវកម្ម ជាពិសេសមូលដ្ឋានអាជីវកម្មពាក់ព័ន្ធនឹងវិស័យទេសចរណ៍ក្នុងខេត្តកែបដែលស្ថិតនៅក្នុងតំបន់ដែលពុំទាន់មានបណ្តាញអគ្គិសនីទៅដល់
- សិក្សាអំពីតម្រូវការនៃការប្រើប្រាស់អគ្គិសនី នៅក្នុងរយៈពេលមធ្យម និងវែង ជាពិសេសសម្រាប់ត្រៀមខ្លួនទទួលការកើនឡើងនៃចំនួនភ្ញៀវទេសចរ។

➢ **ការពង្រឹងវិស័យផ្គត់ផ្គង់ទឹកស្អាត**

- ពង្រីកប្រព័ន្ធបណ្តាញទុយយោមេនិងបណ្តាញសម្រាប់ចែកចាយទឹកស្អាត ឱ្យបានដល់ផ្លូវគ្រប់ភូមិ ឃុំ សង្កាត់ ទាំងអស់នៃក្រុងកែបនិងស្រុកដំណាក់ចង្អើរ និងតភ្ជាប់បណ្តាញនិងដាក់ក្នុងទំរទឹកស្អាតចូលឱ្យដល់គ្រប់មូលដ្ឋានលំនៅឋានប្រជាពលរដ្ឋ ក៏ដូចជាមូលដ្ឋានអាជីវកម្ម

- ផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត និងផលប៉ះពាល់នៃការប្រើប្រាស់ទឹកស្រះ ត្រពាំង អូរ និងអណ្ដូងខ្វង
- ធ្វើអធិការកិច្ច ត្រួតពិនិត្យ និងតាមដានគុណភាពទឹកស្អាតឱ្យបានជាប្រចាំ រួមជាមួយនឹងការពង្រឹងប្រសិទ្ធភាពនៃការចែកចាយទឹកស្អាតឱ្យបានគ្រប់គ្រាន់ ទាំងនៅក្នុងក្រុងកែប និងនៅក្នុងស្រុកដំណាក់ចង្អើរ
- សិក្សាលទ្ធភាពក្នុងការជំរុញការវិនិយោគជាលក្ខណៈទ្រង់ទ្រាយធំនៃវិស័យទឹកស្អាត សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការផ្គត់ផ្គង់ទឹកស្អាតឱ្យដល់គ្រប់លំនៅឋាន ជាពិសេសទៅដល់គ្រប់មូលដ្ឋាននៃសំណង់អគារទាំងអស់។

➢ **ការពង្រឹងវិស័យធនធានទឹក និងគ្រប់គ្រងទឹកជំនន់**

- រៀបចំផែនការគ្រប់គ្រងធនធានទឹកនិងទឹកជំនន់នៅក្នុងស្រុកដំណាក់ចង្អើរនិងក្នុងក្រុងកែប ដោយផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងស្ទឹង អូរ ព្រែក និងដៃព្រែកនានាតភ្ជាប់ទៅនឹងសមុទ្រ និងតំបន់ផ្ទៃរងទឹកភ្លៀង
- សិក្សានិងកំណត់តំបន់សម្រាប់ការសាងសង់អាងស្តុកទឹកយុទ្ធសាស្ត្រក្នុងតំបន់ភ្នំវល្លិ៍ និងការពង្រីកបណ្តាញប្រព័ន្ធរំដោះទឹកភ្លៀងឱ្យបានដល់គ្រប់ទីតាំងភូមិសាស្ត្រក្នុងខេត្តកែប ដើម្បីស្តាក់យកទឹកភ្លៀងសម្រាប់ការប្រើប្រាស់ផង និងចូលរួមកាត់បន្ថយហានិភ័យនៃជំនន់ទឹកភ្លៀងក្នុងតំបន់ទំនាបផង
- បង្កើនកិច្ចសហការ ផ្សព្វផ្សាយ និងផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានស្តីពីអាកាសធាតុ ឧតុនិយម និងការគ្រប់គ្រងធនធានទឹកដល់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេស វិនិយោគិននិងប្រតិបត្តិករក្នុងវិស័យទេសចរណ៍។

➢ **ការពង្រឹងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**

- ពន្លឿននិងពង្រឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញប្រៃសណីយ៍ និងធ្វើទំនើបកម្មប្រព័ន្ធអេក្ទ្បូស៊ីប្រៃសណីយ៍និងសេវាកម្មប្រៃសណីយ៍ នៅក្នុងភូមិសាស្ត្រខេត្តកែប
- បន្តជំរុញការតភ្ជាប់និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដោយយកចិត្តទុកដាក់លើការពង្រីកវិសាលភាពគ្របដណ្តប់និងពង្រឹងគុណភាពសេវាទូរសព្ទចល័ត ព្រមទាំងបង្កើនការសាងសង់បណ្តាញខ្សែកាបអុបទិកឆ្អឹងខ្នង និងខ្សែកាបអុបទិកចែកចាយអ៊ីនធឺណិតល្បឿនលឿនទៅគ្រប់ទីកន្លែងក្នុងប៉ូលទេសចរណ៍ទាំងបួននៃខេត្តកែប
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល តាមរយៈការពន្លឿនកិច្ចដំណើរការបរិវត្តកម្មឌីជីថលក្នុងវិស័យទេសចរណ៍ ឌីជីថលនីយកម្មព័ត៌មានឬទិន្នន័យផលិតផលទេសចរណ៍ សកម្មភាពទេសចរណ៍ ធនធានទេសចរណ៍ ការបង្កើតម៉ាកសញ្ញា ព្រមទាំងការពិនិត្យតាមដានការបំពុលបរិស្ថាន សំដៅពង្រឹងប្រសិទ្ធភាពការផ្សព្វផ្សាយ ការគ្រប់គ្រងភ្ញៀវទេសចរតម្រង់ទិសឆ្ពោះទៅអភិវឌ្ឍទេសចរណ៍ឆ្លាតវៃ។

### ៣.៣.២- យុទ្ធសាស្ត្រពង្រឹងខ្សែច្រវាក់ផលិតកម្មក្នុងវិស័យទេសចរណ៍ខេត្តកែប

ចងក្រងនិងពង្រឹងខ្សែច្រវាក់ផលិតកម្មក្នុងវិស័យទេសចរណ៍ ជាកិច្ចការចាំបាច់ក្នុងការធានាការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការរបស់ភ្ញៀវទេសចរនិងអាជីវកម្មនៅក្នុងមូលដ្ឋាន និងជាពិសេសធានាការអភិវឌ្ឍប្រកបដោយបរិយាបន្ននិងសមធម៌។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការដូចខាងក្រោម ដើម្បីពង្រឹងខ្សែច្រវាក់ផលិតកម្មក្នុងវិស័យទេសចរណ៍ខេត្តកែប៖

- ចងក្រងបណ្ដាញអ្នកផ្គត់ផ្គង់ ដូចជាប្រជាពលរដ្ឋដាំបន្លែនិងដំណាំដាំដុះ ម្ចាស់ចំការ ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វយកសាច់ និងសហគមន៍នេសាទជាដើម ដើម្បីឈានទៅកំណត់ពីប្រភេទនិងបរិមាណនៃការផ្គត់ផ្គង់ផលិតផលក្នុងទីផ្សារ និងធ្វើការចងក្រងបណ្ដាញអ្នកទិញតាមប៉ូលទេសចរណ៍នីមួយៗ ដើម្បីកំណត់ពីប្រភេទនិងបរិមាណនៃតម្រូវការផលិតផលក្នុងទីផ្សារ
- រៀបចំវេទិកាធ្វើការផ្គូផ្គងនិងសម្របសម្រួលរវាងអ្នកផ្គត់ផ្គង់និងអ្នកទិញ អំពីតម្លៃលក់ បរិមាណផ្គត់ផ្គង់ និងគុណភាព ដើម្បីធានាថា ការផលិតឆ្លើយតបនឹងតម្រូវការ
- សិក្សានិងបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការគ្រប់គ្រងច្រវាក់ផលិតកម្មក្នុងវិស័យទេសចរណ៍ខេត្តកែប។

## ៤- យន្តការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តផែនការមេ

### ៤.១. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្ត **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ ២០២៣-២០៣៥"** រាជរដ្ឋាភិបាលបានពិនិត្យឃើញនូវភាពចាំបាច់ក្នុងការកំណត់យន្តការស្ថាប័នច្បាស់លាស់ ដែលទទួលបន្ទុកអនុវត្តផែនការមេនេះ ដែលមានរចនាសម្ព័ន្ធនិងមានសមាសភាព ដូចខាងក្រោម៖

**យន្តការស្ថាប័នគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប**



- **គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍**

គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ជាសេនាធិការជូនរាជរដ្ឋាភិបាល មានតួនាទីនិងភារកិច្ច ដូចមានចែងក្នុងអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

- **គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា**

គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា នឹងត្រូវបានបង្កើតឡើង ដែលមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន ព្រមទាំងមានសមាសភាពថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នពាក់ព័ន្ធជាអនុប្រធាន និងជាសមាជិក ដើម្បីបំពេញមុខងារជាសេនាធិការជូនគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ក្នុងការសម្របសម្រួល ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥ ។ គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា មានតួនាទីនិងភារកិច្ចចម្បងៗ ដូចខាងក្រោម៖

- សម្របសម្រួលនិងអនុវត្តផែនការសកម្មភាពនៃ"**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥**"
- ត្រួតពិនិត្យ តាមដាន វាយតម្លៃ តម្រង់ទិស និងធ្វើបច្ចុប្បន្នកម្ម"**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥**" ស្របតាមការវិវត្តជាក់ស្តែងនៃវិស័យទេសចរណ៍ជាតិ តំបន់ និងសកលលោក
- សិក្សា និងរៀបចំសេចក្តីព្រាងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកំពតនិងខេត្តកោះកុង ឱ្យមានសមាហរណកម្មនិងអភិបាលកិច្ចយុទ្ធសាស្ត្រ សំដៅបង្កើនភាពទាក់ទាញនិងប្រកួតប្រជែងកាន់តែខ្ពស់នៃគោលដៅទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជានៅលើឆាកអន្តរជាតិ
- ពិនិត្យនិងផ្តល់យោបល់ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចលើគម្រោងវិនិយោគទេសចរណ៍
- ជំរុញការធ្វើពិពិធកម្មផលិតផលទេសចរណ៍ខេត្តកែប និងផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តកែបទៅកាន់ទីផ្សារទេសចរណ៍ជាតិនិងអន្តរជាតិ
- សហការនិងជំរុញការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ ដើម្បីវាស់វែងការអនុវត្តវិធានការគោលនយោបាយនិងផែនការសកម្មភាពនៃផែនការមេនេះ
- រៀបចំកិច្ចប្រជុំរៀងរាល់ឆមាសនិងកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការមេ និងដាក់ចេញនូវយន្តការសម្របសម្រួល ក្នុងករណីផែនការសកម្មភាពណាមួយនៅក្នុងផែនការមេមិនអាចសម្រេចបានតាមលទ្ធផលរំពឹងទុក
- រៀបចំរបាយការណ៍ការងារប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និង
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនពីគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍។

គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា មានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានតួនាទីនិងភារកិច្ច ដូចតទៅ÷

- សម្របសម្រួលសកម្មភាពការងារប្រចាំថ្ងៃរបស់គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំកិច្ចប្រជុំនិងសិក្ខាសាលានានារបស់គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការនិងសម្របសម្រួលការងារជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប និងស្ថាប័នពាក់ព័ន្ធដទៃទៀតតាមការចាំបាច់ និង
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា។

❖ **គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប**

តាមរយៈលិខិតលេខ ០២៧/២០ ស.ស.រ. ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ដែលមានអភិបាលនៃគណៈអភិបាលខេត្តកែបជាប្រធាន និងមានមន្ទីរអង្គភាពគ្រប់ជំនាញពាក់ព័ន្ធក្នុងខេត្តជាសមាជិក ដែលមានតួនាទីនិងភារកិច្ចបន្ថែម ដូចតទៅ÷

- អនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥ សម្រាប់តំបន់ប៉ូលទេសចរណ៍ទាំងបួន
- លើកយោបល់ជូនគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា ក្នុងការបង្កើតផលិតផលទេសចរណ៍ថ្មីៗ ដែលនឹងក្លាយជាជម្រើសផលិតផលទេសចរណ៍ដ៏សម្បូណ៌បែបសម្រាប់ទទួលនិងពន្យារការស្នាក់របស់ភ្ញៀវទេសចរ នៅក្នុងខេត្តកែបឱ្យបានកាន់តែយូរ
- ពង្រឹងគុណភាពផលិតផលនិងសេវាកម្មទេសចរណ៍ និងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់តំបន់ប៉ូលទេសចរណ៍ទាំងបួន តាមដំណាក់កាល ឆ្ពោះទៅសម្រេចបានតាមស្តង់ដាអន្តរជាតិ និងប្រើប្រាស់បច្ចេកវិទ្យាទំនើប
- សិក្សា និងរៀបចំខ្សែទស្សនកិច្ចទេសចរណ៍អន្តរប៉ូលក្នុងខេត្តកែប
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា និង
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់គណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា។

❖ **មជ្ឈមណ្ឌលនវានុវត្តន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា**

មជ្ឈមណ្ឌលនវានុវត្តន៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា នឹងត្រូវបានបង្កើតឡើងដើម្បីសិក្សាតាមដានពីស្ថានភាពវិវត្តនៃវិស័យទេសចរណ៍កម្ពុជា តំបន់ និងសកលលោក ជាពិសេសវិស័យទេសចរណ៍តំបន់ឆ្នេរ សំដៅរៀបចំយុទ្ធសាស្ត្រជំរុញការអភិវឌ្ឍទេសចរណ៍នៃខេត្តតំបន់ឆ្នេរសមុទ្រទាំងបួន ឱ្យកាន់តែមានភាពទាក់ទាញ មានភាពប្រកួតប្រជែងនិងភាពច្នៃប្រឌិតខ្ពស់ ស្របតាមចក្ខុវិស័យនិងបរិបទពិភពលោក។ មជ្ឈមណ្ឌលនេះមានតួនាទីនិងភារកិច្ច ដូចតទៅ÷

- សិក្សាស្រាវជ្រាវនិងតាមដានអំពីស្ថានភាពនិងការវិវត្តនៃវិស័យទេសចរណ៍ខេត្តទាំងបួនក្នុងតំបន់ឆ្នេរសមុទ្រ វិស័យទេសចរណ៍ក្នុងស្រុកទាំងមូល ក្នុងតំបន់ និងលើសកលលោក
- ស្រាវជ្រាវបង្កើតផលិតផលទេសចរណ៍ថ្មីៗ ជាពិសេសផលិតផលទេសចរណ៍ដែលប្រើប្រាស់បច្ចេកវិទ្យាទំនើប សំដៅបង្កើនឧត្តមភាពប្រកួតប្រជែងក្នុងនិន្នាការសេដ្ឋកិច្ចឌីជីថល
- ប្រមូលនិងវិភាគនូវរាល់ព័ត៌មានឬទិន្នន័យដែលទទួលបាន រួចផ្តល់ជាយោបល់និងអនុសាសន៍ជូនគណៈកម្មាធិការ ឬគណៈកម្មការពាក់ព័ន្ធ ដែលមានតួនាទីជំរុញការអភិវឌ្ឍ វិស័យទេសចរណ៍ខេត្តកែប និង
- ចូលរួមកិច្ចប្រជុំតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការមេ និងបំពេញភារកិច្ចផ្សេងទៀតតាមការចាំបាច់។

ជាមួយនឹងស្ថាប័នទាំងឡាយខាងលើ ការអនុវត្ត "**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ ២០២៣-២០៣៥**" ក៏មានការចូលរួមផ្តល់ធាតុចូលពីសំណាក់ស្ថាប័នគាំទ្រសំខាន់ៗមួយចំនួនផ្សេងទៀត ដើម្បីជួយទម្រង់ទិសនិងលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប ស្របតាមសមត្ថកិច្ច និងជំនាញរបស់ស្ថាប័នទាំងនោះ។ ស្ថាប័នគាំទ្រទាំងនោះ រួមមានដូចជា គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា និងក្រសួង ស្ថាប័នជំនាញនានា។

## ៤.២- ប្រភពហិរញ្ញប្បទានគាំទ្រដល់ការអនុវត្តផែនការមេ

ការអនុវត្ត "ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥" ទាមទារឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុនិងថវិកា ដែលមានប្រភពមកពី÷

– ហិរញ្ញប្បទានពីថវិការាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងអង្គការជាតិ អន្តរជាតិនានា
– ការវិនិយោគរបស់វិស័យឯកជន ទាំងវិនិយោគិនក្នុងស្រុកនិងពីបរទេស និងការសហការវិនិយោគរវាងវិស័យសាធារណៈ ឯកជន និងសហគមន៍មូលដ្ឋាន ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និង

- ប្រភពថវិកាស្របច្បាប់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្ត ប្រើប្រាស់សម្រាប់ការអភិវឌ្ឍក្នុងប៉ូលនីមួយៗ និងចំណូលទទួលបានពីសកម្មភាពទេសចរណ៍។

## ៥- ការគ្រប់គ្រងហានិភ័យ

ការសម្រេចបានជោគជ័យប្រកបដោយផ្លែផ្កា ក្នុងការអនុវត្ត "**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥**" ទាមទារឱ្យមានភាពបុរេសកម្មក្នុងការកំណត់ហានិភ័យ និងត្រៀមលក្ខណសម្បត្តិដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ ដែលអាចកើតមានឡើយជាយថាហេតុ និងអាចបន្ទុចបង្អាក់ដល់ការអនុវត្តផែនការមេនេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់នូវហានិភ័យមួយចំនួន ដូចខាងក្រោម ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ ពីសំណាក់ក្រសួង ស្ថាប័នមានសមត្ថកិច្ច÷

**ហានិភ័យខាងក្រៅ**: ការអភិវឌ្ឍវិស័យទេសចរណ៍ជារួម ពឹងផ្អែកមួយចំណែកធំលើចលនានិងការមកដល់នៃភ្ញៀវទេសចរអន្តរជាតិ។ ក្នុងបរិការណ៍បច្ចុប្បន្ន ដែលពិភពលោកប្រឈមនឹងហានិភ័យនៃភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ចសកល បញ្ហាភូមិសាស្រ្តនយោបាយ និងការបន្តគំរាមកំហែងពីសំណាក់ជំងឺកូវីដ-១៩និងជំងឺឆ្លងផ្សេងទៀត ចលនា និងសកម្មភាពទេសចរណ៍អន្តរជាតិ នៅស្ថិតក្នុងស្ថានភាពផុយស្រួយដែលនាំឱ្យការអភិវឌ្ឍវិស័យទេសចរណ៍ជារួមនៅមានភាពមិនប្រាកដប្រជាខ្ពស់។ ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនេះ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវចូលរួមលើកកម្ពស់ភាពធន់នៃការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងខេត្តកែបនិងក្នុងប្រទេសកម្ពុជា តាមរយៈការជំរុញឱ្យមានសកម្មភាពទេសចរណ៍ផ្ទៃក្នុងកាន់តែច្រើន និងចូលរួមលើកកម្ពស់ភាពធន់នៃសកម្មភាពអាជីវកម្មនៅតាមមូលដ្ឋានទាំងអស់។

**ហានិភ័យក្នុងស្រុក**: ការអនុវត្ត "ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥" ក៏ជួបប្រទះនូវហានិភ័យក្នុងស្រុកមួយចំនួន ពាក់ព័ន្ធនឹងកត្តាប្រជាសាស្រ្តនិងភាពស្មុគស្មាញនៃការអនុវត្តផែនការមេនេះ។ ខេត្តកែបជាខេត្តតូច និងមានប្រជាជនភាគច្រើនប្រកបរបរចិញ្ចឹមជីវិតក្រៅពីវិស័យទេសចរណ៍ ដែលកត្តានេះអាចនាំឱ្យមានការខ្វះខាតនូវធនធានមនុស្សសម្រាប់បម្រើឱ្យវិស័យទេសចរណ៍ ជាពិសេសនៅពេលដែលវិស័យទេសចរណ៍នៅក្នុងខេត្តកែបមានការលូតលាស់លឿនជាងការរំពឹងទុក។ម្យ៉ាងទៀត ដូចបានបង្ហាញខាងលើ ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តកែប គឺជាកិច្ចការដែលទាមទារឱ្យមានការចូលរួមពីសំណាក់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់កម្រិតទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។ អាស្រ័យហេតុនេះ ក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ នឹងសហការឱ្យបានជិតដិត ដើម្បីធានាការអនុវត្តផែនការមេនេះប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព។

ឆ្លើយតបទៅហានិភ័យខាងលើ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥ ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកថាជា "**ឯកសាររស់**" ដែលអាចត្រូវបានកែប្រែឱ្យសមស្របតាមស្ថានភាពការណ៍ និងការវិវត្តជាក់ស្តែងនៃវិស័យទេសចរណ៍ និងទិដ្ឋភាពពាក់ព័ន្ធនានា។

## ៦- សេចក្តីសន្និដ្ឋាន

ដើម្បីកំណត់ទិសដៅនៃការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប និងលើកស្ទួយវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឱ្យអនុវត្តនូវ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥"** សំដៅអភិវឌ្ឍខេត្តកែបឱ្យក្លាយជាគោលដៅទេសចរណ៍ និងជាមេដែកទាក់ទាញនៅតំបន់ឆ្នេរដ៏សំខាន់និងប្រកបដោយសក្តានុពលមួយ និងបង្កើនឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារទេសចរណ៍អន្តរជាតិ ជាពិសេសចាប់យកកាលានុវត្តភាពថ្មីៗ ក្នុងបរិការណ៍ដែលទីផ្សារទេសចរណ៍សកលកំពុងតែមានការប្រែប្រួល។ ស្របតាមសក្តានុពលរបស់ខេត្តកែប ដែលជាខេត្តមានធនធានធម្មជាតិ និងវប្បធម៌ជាច្រើន ផែនការមេនេះបានកំណត់ចក្ខុវិស័យប្រែក្លាយខេត្តកែបជា**"គោលដៅទេសចរណ៍ធម្មជាតិនិងសមុទ្រសម្រាកកម្សាន្តបែបប្រណិតកម្រិតខ្ពស់"**។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ផែនការមេនេះបានកំណត់យុទ្ធសាស្ត្រចំនួន៣ ដែលក្នុងនោះ រួមមានៈ ទី១) យុទ្ធសាស្ត្រអភិវឌ្ឍន៍ប៉ូលទេសចរណ៍ខេត្តកែប ទី២) យុទ្ធសាស្ត្រលើកកម្ពស់ការវិនិយោគ អភិវឌ្ឍធនធានមនុស្ស និងផ្សព្វផ្សាយទីផ្សារ និងទី៣) យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ខេត្តកែប។

ឈរលើទស្សនាទាន **"ការអភិវឌ្ឍវិស័យទេសចរណ៍ ត្រូវមានការគាំទ្រពីការអភិរក្សនិងការអភិវឌ្ឍនៃគ្រប់វិស័យ ពិសេសធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធគោល និងការតភ្ជាប់គមនាគមន៍"** ផែនការមេនេះតម្រូវឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាព និងសហថាមភាពនៃយុទ្ធសាស្ត្រនីមួយៗ ក្នុងការជំរុញនិងលើកកម្ពស់វិស័យទេសចរណ៍នៃខេត្តកែប។ ការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃផែនការមេនេះ នឹងដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍និងសេដ្ឋកិច្ចនៃខេត្តកែបទាំងមូល និងបើកឱ្យមានឱកាសការងារជាច្រើនថែមទៀត និងចូលរួមលើកកម្ពស់ជីវភាពដល់ប្រជាជននៅក្នុងមូលដ្ឋាន។ ជាមួយគ្នានេះ ការអនុវត្តផែនការមេនេះបានជោគជ័យ នឹងលើកមុខលើកមាត់ប្រទេសកម្ពុជាជាគោលដៅទេសចរណ៍ដ៏សំខាន់មួយក្នុងតំបន់ និងរួមចំណែកក្នុងការលើកស្ទួយវិស័យទេសចរណ៍ឱ្យក្លាយជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាថ្មីម្តងទៀត ដើម្បីរួមចំណែកក្នុងការជំរុញការអភិវឌ្ឍប្រទេសជាតិទាំងមូល។

ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែបត្រូវបានរំពឹងថា នឹងទទួលបានប្រយោជន៍ដ៏ធំធេងបន្ថែមទៀតពីគម្រោង **"ព្រែកជីកហ្វូណនតេជោ"** ដែលត្រូវបានអនុញ្ញាតឱ្យមានការសិក្សាដោយរាជរដ្ឋាភិបាល។ គម្រោងនេះអាចនឹងក្លាយជាហេដ្ឋារចនាសម្ព័ន្ធមួយ ដែលតភ្ជាប់ប៉ូលទេសចរណ៍សំខាន់ៗនៃព្រះរាជាណាចក្រកម្ពុជា ដូចជាប៉ូលអភិវឌ្ឍទេសចរណ៍តំបន់ទន្លេមេគង្គ ប៉ូលទេសចរណ៍តំបន់ទន្លេសាប និងប៉ូលទេសចរណ៍តំបន់ភ្នំពេញ ជាមួយនឹងខេត្តកែប ព្រមទាំងដើរតួជាហេដ្ឋារចនាសម្ព័ន្ធគោលយ៉ាងសំខាន់ ដើម្បីលើកកម្ពស់ការដឹកជញ្ជូន វិស័យកសិកម្មនិងជលផល និងបរិស្ថាន ដែលសុទ្ធសឹងតែជាកត្តាយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៃខេត្តកែប។ ក្នុងស្មារតីនេះ "ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២៣-២០៣៥" អាចនឹងត្រូវបានកែសម្រួលបន្ថែមទៀត ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីលក្ខានុពលនៃគម្រោងនេះ។

# ឧបសម្ព័ន្ធទី១: តារាងផែនការសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ និងវិស័យនានាគាំទ្រវិស័យទេសចរណ៍ក្នុងខេត្តកែប ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០៣៥

## ឧបសម្ព័ន្ធទី១: តារាងផែនការសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ និងវិស័យនានាគាំទ្រវិស័យទេសចរណ៍ក្នុងខេត្តកែប

## ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០៣៥

| ល.រ | មុខសញ្ញាការងារ | វិធានការ | សកម្មភាពការងារ | ទីតាំងគម្រោង | អង្គភាពទទួលបន្ទុក | រយៈពេលនៃការអនុវត្ត | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ខ្លី | | | | | មធ្យម | | | | | វែង | | |
| | | | | | | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ៣២ | ៣៣ | ៣៤ | ៣៥ |
| **ក្របខំណ្ឌយុទ្ធសាស្ត្រ** | | | | | | | | | | | | | | | | | | |
| I- | យុទ្ធសាស្ត្រអភិវឌ្ឍន៍ប៉ូលទេសចរណ៍ខេត្តកែប | | | | | | | | | | | | | | | | | |
| ១- | ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់ក្រុងកែបជា "ទីក្រុងធម្មជាតិក្នុងឧទ្យានប្រណិតកម្រិតពិភពលោក" | | | ក្រុងកែប | | | | | | | | | | | | | | |
| ១.១- | អភិវឌ្ឍទេសចរណ៍ធម្មជាតិកម្រិតខ្ពស់ក្នុងឧទ្យាន-ជាតិកែប | ១- ជំរុញការវិនិយោគគម្រោងអភិវឌ្ឍអេកូទេសចរណ៍គុណភាពនៅឧទ្យានជាតិកែប | ▪ សិក្សានិងជំរុញការវិនិយោគគម្រោងអភិវឌ្ឍអេកូ-ទេសចរណ៍គុណភាព ក្នុងទម្រង់ជារមណីយដ្ឋាន ឬសណ្ឋាគារកម្រិតផ្កាយបួន<br>▪ ពង្រឹងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាសម្រាប់រមណីយ-ដ្ឋានទេសចរណ៍(SOP)។ | ក្រុងកែប | ក.ទ.ច<br>ក.ប.ស្ថ<br>រ.ប.ក | | √ | √ | √ | √ | | | | | | | | |
| | | ២-ពង្រឹងការទទួលខុសត្រូវរបស់គម្រោងវិនិយោគនៅក្នុងឧទ្យានជាតិកែប | ▪ ជំរុញការផ្សព្វផ្សាយ ដោយផលិតផលទេសចរណ៍ទាំងអស់ត្រូវគោរពនិងស្របតាមគោលការណ៍នៃការកំណត់តំបន់ប្រើប្រាស់ដោយចីរភាព ដោយបន្សីទៅនឹងបទប្បញ្ញត្តិនគរូបនីយកម្មសម្រាប់ការអភិរក្សការអភិវឌ្ឍ និងការសាងសង់ក្នុងក្របខ័ណ្ឌតំបន់ឆ្នេរពិសេសប្លង់គោលប្រើប្រាស់ដីក្រុងកែប។ | ក្រុងកែប | រ.ប.ក | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៣-ជំរុញការអភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធ | ▪ សិក្សា និងស្ថាបនាផ្លូវក្នុងឧទ្យានបន្ថែមទៀត ជាមួយនឹងការបំពាក់ភ្លើងបំភ្លឺសាធារណៈ និងស្លាកសញ្ញាបង្ហាញផ្លូវគ្រប់គ្រាន់ | ក្រុងកែប | ក.ទ.ច<br>ក.ប.ស្ថ<br>រ.ប.ក | √ | √ | √ | √ | √ | √ | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | នានាក្នុងតំបន់ឧទ្យានជាតិ | ▪ សិក្សាលទ្ធភាពបន្ថែមចំនួនឧទ្យានុរក្សប្រចាំការ<br>▪ សិក្សាបង្កើតបន្ថែមច្រកចូលទស្សនាឧទ្យាន អម ដោយទីតាំងលក់សំបុត្រនិងមណ្ឌលព័ត៌មាន<br>▪ សិក្សា បង្កើតមគ្គុទ្ទេសក៍ឧទ្យានជាតិកែបដែលទទួលបានការបណ្តុះបណ្តាលស្របតាមស្តង់ដាត្រឹមត្រូវ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់ព័ត៌មាន និងទាក់ទាញភ្ញៀវទេសចរបន្ថែម។ | | | | | | | | | | | | | | | |
| | | ៤-ការពារ និងកែលម្អអាងស្តុកទឹកប៉ោហេង និងតំបន់ផ្ទៃរងទឹកភ្លៀងជុំវិញ | ▪ រៀបចំផែនការការពារ និងនិងកែលម្អអាងស្តុកទឹកប៉ោហេង និងតំបន់ផ្ទៃរងទឹកភ្លៀងជុំវិញ សម្រាប់រៀបចំកែលម្អជាគោលដៅទាក់ទាញទេសចរមកកម្សាន្តផង ជាប្រភពផ្គត់ផ្គង់ទឹកនៅក្នុងប៉ូលទេសចរណ៍តំបន់ក្រុងកែបចាស់ផង និងជាប្រភពទឹកគាំទ្រដល់ការរស់នៅរបស់សត្វនិងជីវៈចម្រុះនានា។ | ក្រុងកែប | ក.ប.ស្ព<br>ក.ធ.ឱ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៥-ដាក់ចេញយុទ្ធនាការឧទ្យានកែប និងកោះទន្សាយគ្មានសំណល់ប្លាស្ទិកត្រឹមឆ្នាំ២០៣០ | ▪ ពង្រឹងការគ្រប់គ្រងសំណល់រឹងក្នុងតំបន់ឧទ្យានជាតិកែបជាគោលដៅគ្មានសំណល់ប្លាស្ទិកត្រឹមឆ្នាំ២០៣០។ | ខេត្តកែប | ក.ប.ស្ព<br>ក.ធ.ឱ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ១.២- | អភិវឌ្ឍទេសចរណ៍ក្រុងបេតិកភណ្ឌ | ១- រៀបចំយន្តការ និងផែនការអភិរក្សសំណង់បេតិកភណ្ឌក្នុងទីក្រុងកែប | សិក្សា រៀបចំផែនការអភិរក្ស កែលម្អសោភ័ណភាព និងអភិវឌ្ឍបន្ថែម÷<br>▪ ព្រះរាជដំណាក់នៅពយដំណាក់ស្តេច និង ព្រះរាជដំណាក់ព្រះមហាក្សត្រិយានីនារីរតន៍កុសុមៈ | ក្រុងកែប | ក.វ.វ.ស<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | រួមនឹងផៃបុរាណនៅមុខព្រះរាជដំណាក់ មហាក្សត្រិយានីនារីរតន៍កុសុមៈ<br>▪ សំណង់ស្ថាបត្យកម្មដែលបន្សល់ទុកពីជំនាន់សម័យ អាណានិគមនៅក្នុងប្លុកក្រុងកែប<br>▪ សំណង់អតីតផ្ទះទឹមដុងនៅជិតប្លុកឆ្នេរលេងទឹក។ | | | | | | | | | | | | | | | |
| | | ២- សិក្សាស្រាវជ្រាវអំពីទីទួលបុរាណ | ▪ សិក្សាស្រាវជ្រាវអំពីទីទួលបុរាណដ្ឋាននានាក្នុងភូមិសាស្ត្រខេត្តកែបទាំងមូល សម្រាប់គាំទ្រដល់សកម្មភាពទេសចរណ៍ក្រុងបេតិកភណ្ឌ ទេសចរណ៍ប្រវត្តិសាស្ត្រ និងទេសចរណ៍វប្បធម៌។ | ខេត្តកែប | ក.វ.វ.ស<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ១.៣- | អភិវឌ្ឍគោលដៅអេកូ-ទេសចរណ៍ព្រៃកោងកាងអូរក្រសារ និងភូមិថ្មី | ១- ពង្រឹងការគ្រប់គ្រងសហគមន៍ទេសចរណ៍ព្រៃកោងកាងអូរក្រសារនិងភូមិថ្មី | ▪ ពង្រឹងការគ្រប់គ្រងសហគមន៍ព្រៃកោងកាងអូរក្រសារនិងភូមិថ្មី ដើម្បីអភិរក្ស និងលើកកម្ពស់ធនធានជីវៈចម្រុះនិងព្រៃកោងកាងក្នុងតំបន់។ | ក្រុងកែប | ក.ទ.ច<br>ក.ស.ក<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ២-ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានាសម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យទេសចរណ៍ | ▪ ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានាសម្រាប់ការអភិវឌ្ឍក្នុងសហគមន៍ទេសចរណ៍ព្រៃកោងកាងអូរក្រសារនិងភូមិថ្មី ទាំងពេលថ្ងៃនិងពេលរាត្រី ពិសេស ការចិញ្ចឹមអំពិលអំពែកឡើងវិញ ដើម្បីបង្កើតទស្សនីយភាពដ៏ទាក់ទាញនៅពេលយប់។ | ក្រុងកែប | ក.ទ.ច<br>ក.ស.ក<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.៤ | កែលម្អនិងលើកកម្ពស់ភាពទាក់ទាញទេសចរណ៍ក្រុងកែប | ១-កែលម្អគោលដៅកម្សាន្តសំខាន់ៗ | ▪ រៀបចំកែលម្អគោលដៅកម្សាន្តសំខាន់ៗ ក្នុងការត្រៀមទទួលស្វាគមន៍ភ្ញៀវទេសចរមកសម្រាកលេងកម្សាន្ត រួមមាន ១)- ការរៀបចំកែលម្អតូបកម្សាន្តនៅតាមបណ្តោយឆ្នេរនិងមុខសាលាខេត្ត (ដូចក្នុងរូបភាពទី៣ ទំព័រទី១៥) ២)- ការកែលម្អផ្សារក្តាម ផ្សារសេះស ផ្សារកែបនិងតំបន់ជុំវិញ និង ៣)- ការរៀបចំកែលម្អតំបន់ឆ្នេរកែប។ | ក្រុងកែប | គ.អ.ធ.ក<br>រ.ប.ក | √ | √ | √ | √ | √ | √ | | | | | | | |
| | | ២-រៀបចំជាក្រុងនិរន្តរភាពអាស៊ាន និងក្រុងបេតិកភណ្ឌ | ▪ ដាក់ចេញផែនការនិងយុទ្ធនាការក្រុងកែប ជាក្រុងនិរន្តរភាពអាស៊ានទាំងបីសូចនាករ (ទឹកស្អាត ដីស្អាត និងខ្យល់ស្អាត) មុនឆ្នាំ២០៣០ និងជាក្រុងបេតិកភណ្ឌរបស់ UNESCO មុនឆ្នាំ២០៣៥។ | ក្រុងកែប | ក.ប.ស្ថ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៣-ជំរុញការរៀបចំសួនសាធារណៈ | ▪ សិក្សានិងជំរុញការរៀបចំសួនសាធារណៈ និងទេសភាពបៃតងសាធារណៈ Green Landscape។ | ខេត្តកែប | ក.ប.ស្ថ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៤- កំណត់តំបន់គ្មានយានយន្តនាចុងសប្តាហ៍ក្នុងក្រុងកែប | ▪ សិក្សាលទ្ធភាពក្នុងការរៀបចំតំបន់គ្មានយានយន្តនាចុងសប្តាហ៍ក្នុងក្រុងកែប ដោយជ្រើសយកផ្លូវ ដែលមិនប៉ះពាល់ដល់ចរាចរណ៍ឆ្លងកាត់ខេត្ត។ | ក្រុងកែប | ក.សាធា<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៥- ពង្រឹងការត្រួតពិនិត្យស្លាកយីហោ | ▪ ពង្រឹងការត្រួតពិនិត្យស្លាកយីហោ ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រកម្ពុជានិងអត្តសញ្ញាណវប្បធម៌ជាតិ តាមរយៈការពង្រឹងការអនុវត្តលិខិតលេខ៣៣២២ ជនស/គ.អ.ធ.ក. ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការប្រើប្រាស់អក្សរខ្មែរនិងអក្សរបរទេសនៅផ្ទាំងគំនូរសំណង់ ឬផ្លាកសញ្ញាផ្សព្វផ្សាយនៅតាមតំបន់ឆ្នេរ។ | ខេត្តកែប | ក.វ.វ.ស<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ៦-អភិវឌ្ឍទេសចរណ៍សាសនា | ▪ អភិវឌ្ឍទេសចរណ៍សាសនា តាមរយៈការសិក្សានិងរៀបចំវត្តអារាមនិងទីសក្ការៈនានាក្នុងខេត្តកែបឱ្យកាន់តែមានភាពទាក់ទាញ ដូចជាមណ្ឌលសាសនានៅភ្នំសសៀរ និងមណ្ឌលសមាធិនៅវត្តសមុទ្ររង្សីជាដើម។ | ក្រុងកែប | ក.វ.វ.ស<br>រ.ប.ក | √ | √ | √ | | | | | | | | | | |
| | | ៧-អភិវឌ្ឍ និងពង្រឹងការគ្រប់គ្រងផ្សារសាធារណៈប្រណិតកម្រិតខ្ពស់ | ▪ អភិវឌ្ឍនិងពង្រឹងការគ្រប់គ្រងផ្សារសាធារណៈប្រណិតកម្រិតខ្ពស់ ជាពិសេស ពិនិត្យលទ្ធភាពរៀបចំកែលម្អជាផ្សារកម្សាន្តនៅតាមទីតាំងសក្តានុពល រួមមានតំបន់ផ្សារនៅទល់មុខសាលាខេត្តកែបនិងនៅជិតព្រំប្រទល់ក្រុងកែបនិងស្រុកដំណាក់ចង្អើរ សំដៅជំរុញការធ្វើពិពិធកម្មផលិតផលទេសចរណ៍ផ្សារខ្យាច់ឱ្យកាន់តែសម្បូណ៌បែប។ | ក្រុងកែប | គ.អ.ធ.ក<br>រ.ប.ក | √ | √ | √ | √ | | | | | | | | | |
| ២- | **ការអភិវឌ្ឍប៉ូលទេសចរណ៍តំបន់អង្គោលជា "តំបន់ទេសចរណ៍ផ្សារសមុទ្រធម្មជាតិបែបទំនើប"** | | | | | | | | | | | | | | | | | |
| ២.១- | អភិវឌ្ឍទេសចរណ៍ស្រែអំបិល | ១- ជំរុញការរៀបចំតំបន់ស្រែអំបិល ជាគោលដៅ កសិ-ទេសចរណ៍ស្រែអំបិល | ▪ សិក្សា ជំរុញនិងគាំទ្រប្រែក្លាយតំបន់ស្រែអំបិលសក្តានុពលមួយចំនួននៅតំបន់អង្គោលនិងក្រុងកែបជាគោលដៅកសិទេសចរណ៍ស្រែអំបិល ដោយមានការរៀបចំជាសកម្មភាពផ្សេងៗ ដោយផ្តល់បទពិសោធដល់ភ្ញៀវទេសចរក្នុងការចូលរួមក្នុងសកម្មភាពផលិតកម្មអំបិល ដើម្បីជាការសិក្សា ផងនិងជាសកម្មភាពកម្សាន្តផង។ | ខេត្តកែប | ក.ឧ.វ<br>រ.ប.ក | √ | √ | √ | | | | | | | | | | |
| | | ២- ពង្រឹងសមត្ថភាពសហគមន៍ | ▪ ពង្រឹងសមត្ថភាពសហគមន៍ក្នុងការទទួលភ្ញៀវទេសចរ ព្រមទាំងប្រើប្រាស់បច្ចេកទេសនិងវិធីសាស្ត្រផលិតកម្មអំបិល ដែលមានភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរ។ | តំបន់អង្គោល | ក.ឧ.វ.ប.ន<br>ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.២- | អភិវឌ្ឍទេសចរណ៍សហគមន៍តំបន់អង្កោល | ១-បង្កើតសហគមន៍ទេសចរណ៍ភ្នំអង្កោល | ▪ រៀបចំបង្កើតសហគមន៍ទេសចរណ៍ភ្នំអង្កោល សម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍទេសចរណ៍សហគមន៍តំបន់អង្កោល ដោយផ្តោតលើការផ្តល់បទពិសោធជីវភាពក្នុងទីជនបទ ដល់ភ្ញៀវទេសចរ។ | តំបន់អង្កោល | ក.ទ.ច<br>រ.ប.ក | √ | √ | | | | | | | | | | | |
| | | ២-សិក្សានិងជំរុញការបង្កើតសកម្មភាពកម្សាន្តថ្មីៗក្នុងភូមិ | ▪ សិក្សាលទ្ធភាពពង្រីកសកម្មភាពកម្សាន្តបន្ថែមជុំវិញភូមិ ដូចជាការជិះកង់កម្សាន្តក្នុងភូមិ ការជិះទូកទស្សនាព្រៃកោងកាង រុក្ខជាតិអមដោយជីវៈចម្រុះ និងសត្វបក្សីតាមដងព្រែកអង្កោល និងការជិះខ្សែរ៉ូកពីកំពូលភ្នំអង្កោលកាត់តាមសហគមន៍នេសាទមកកាន់ឆ្នេរអង្កោល ជាដើម។ | តំបន់អង្កោល | រ.ប.ក | √ | √ | √ | √ | √ | | | | | | | | |
| | | ៣-កែលម្អឆ្នេរអង្កោលជាគោលដៅឆ្នេរខ្សាច់កម្សាន្ត | ▪ សិក្សា រៀបចំកែលម្អឆ្នេរអង្កោលជាគោលដៅឆ្នេរខ្សាច់កម្សាន្ត និងលើកទឹកចិត្តដល់ការអភិវឌ្ឍរៀបចំបង្កើតទំនប់រលកឬតំបន់ការពាររលកទឹកសមុទ្រ អមដោយផែនការអភិវឌ្ឍកំពង់ផែម៉ារីណាទេសចរណ៍។ | តំបន់អង្កោល | គ.អ.ធ.ក.<br>រ.ប.ក | √ | √ | √ | √ | √ | √ | | | | | | | |
| | | ៤- យុទ្ធនាការបំផុសស្មារតីរៀបចំភូមិស្អាតតាមសហគមន៍ | ▪ រៀបចំយុទ្ធនាការបំផុសស្មារតីរៀបចំភូមិស្អាតតាមសហគមន៍ នៅគ្រប់ទីជនបទក្នុងខេត្តកែបដោយចាប់ផ្តើមពីតំបន់ភ្នំអង្កោល ក្រោមពាក្យស្លោក"ភូមិស្អាតកើតចេញពីប្រជាពលរដ្ឋគំរូ" និង"ភូមិស្អាត ផ្ទះស្អាត់ល្អ បង្កើនប្រាក់ចំណូល" ដើម្បីជំរុញប្រជាជនក្នុងមូលដ្ឋានឱ្យចូលរួមក្នុងការរៀបចំភូមិទេសចរណ៍ និងសហគមន៍ទេសចរណ៍ស្អាត និងការរៀបចំសេវាកម្មស្នាក់នៅតាមសហគមន៍ទូទាំងខេត្តកែបសម្រាប់ទទួលស្វាគមន៍ភ្ញៀវទេសចរ។ | ខេត្តកែប | ក.អ.ជ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.៣- | អភិវឌ្ឍទេសចរណ៍តំបន់ព្រៃកោងកាងនៅព្រំប្រទល់ក្រុងកែបនិងស្រុកដំណាក់ចង្អើរ | ១-រៀបចំផែនការអភិវឌ្ឍតំបន់អេកូទេសចរណ៍ព្រៃកោងកាងកែប-អង្កោល | ▪ សិក្សា រៀបចំផែនការអភិវឌ្ឍតំបន់អេកូទេសចរណ៍ព្រៃកោងកាងកែប-អង្កោល ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវ និងមានការចូលរួមពីសំណាក់ប្រជាជន ម្ចាស់ដី និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីធានាចីរភាពនៃការអភិវឌ្ឍអេកូទេសចរណ៍ក្នុងតំបន់នេះ។ | តំបន់អង្កោល | ក.ទ.ច រ.ប.ក | √ | √ | √ | √ | √ | | | | | | | | |
| ៣- | ការអភិវឌ្ឍប៉ូលទេសចរណ៍ធម្មជាតិតំបន់ភ្នំវល្លិ៍ជា “តំបន់កសិទេសចរណ៍ និងទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ” | | | | | | | | | | | | | | | | | |
| ៣.១- | អភិវឌ្ឍកសិ-ទេសចរណ៍តំបន់ភ្នំវល្លិ៍ | ១-អភិវឌ្ឍកសិ-ទេសចរណ៍តំបន់ភ្នំវល្លិ៍ | ▪ សិក្សា និងរៀបចំចងក្រងទីតាំងដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យកសិ-ទេសចរណ៍ ជាពិសេសនៅតំបន់ចំការម្រេច និងចំការទុរេន ដោយមានកិច្ចសហការឱ្យបានជិតស្និតជាមួយម្ចាស់ចំការ និងប្រជាជនក្នុងមូលដ្ឋាន ដើម្បីរៀបចំសម្បទាទេសចរណ៍ចាំបាច់នានា និងកំណត់ប្រភេទសេវាកម្ម និងផលិតផលទេសចរណ៍ដែលមាននៅតាមទីតាំងនីមួយៗ។ | តំបន់ភ្នំវល្លិ៍ | ក.ស.ក រ.ប.ក | √ | √ | √ | √ | √ | | | | | | | | |
| | | ២-បង្កើនផលិតភាព និងធ្វើពិពិធកម្មផលិតផល | ▪ សិក្សា និងជំរុញការបង្កើនផលិតភាព និងធ្វើពិពិធកម្មផលិតផលកសិកម្មក្នុងខេត្តកែប សំដៅធានានូវការផ្គត់ផ្គង់ ផលិតផលកសិកម្មក្នុងស្រុកក្នុងកម្រិតអតិបរមា ដល់ភ្ញៀវទេសចរ ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តកែបទាំងមូល។ | តំបន់ភ្នំវល្លិ៍ | ក.ស.ក រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | កសិកម្មក្នុងខេត្តកែប | | | | | | | | | | | | | | | | |
| | | ៣- បង្កើតផ្សារផលិតផលកសិកម្មសម្បូរណ៍បែប | ▪ សិក្សា និងពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើតផ្សារផលិតផលកសិកម្មសម្បូរណ៍បែប សំដៅទាក់ទាញភ្ញៀវទេសចរ និងផ្សព្វផ្សាយនូវផលិតផលកសិកម្ម និងកសិឧស្សាហកម្ម ជាពិសេសផលិតផលដែលមានសក្តានុពលក្នុងខេត្តកែប។ | តំបន់ភ្នំវល្លិ៍ | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៣.២- | អភិវឌ្ឍទេសចរណ៍ប្រវត្តិសាស្ត្រសង្គ្រាមនិងទេសចរណ៍ផ្សងព្រេងតំបន់ភ្នំវល្លិ៍ | ១- អភិវឌ្ឍទេសចរណ៍ប្រវត្តិសាស្ត្រសង្គ្រាមតំបន់ភ្នំវល្លិ៍ | ▪ សិក្សាស្រាវជ្រាវលម្អិតអំពីប្រវត្តិសាស្ត្រសង្គ្រាម គួបផ្សំជាមួយនឹងការប្រមូលនូវវត្ថុបុរាណ ដូចជាគ្រឿងយុទ្ធភ័ណ្ឌ និងគ្រឿងសព្វាវុធចាស់ៗ និងរៀបចំបង្កើតភូមិទេសចរណ៍ប្រវត្តិសាស្ត្រ ក្នុងភូមិចំការបីនៃស្រុកដំណាក់ចង្អើរ។ | តំបន់ភ្នំវល្លិ៍ | ក.ទ.ច<br>ក.វ.វ.ស<br>រ.ប.ក | √ | √ | √ | | | | | | | | | | |
| | | ២- អភិវឌ្ឍទេសចរណ៍ផ្សងព្រេងតំបន់ភ្នំវល្លិ៍ | ▪ ពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើនៅក្នុងតំបន់ភ្នំវល្លិ៍ និងសិក្សា កំណត់តំបន់ និងផ្លូវខ្សែទស្សនកិច្ចទេសចរណ៍សម្រាប់សកម្មភាពផ្សងព្រេងកម្សាន្តក្នុងព្រៃ និងរៀបចំបង្កើតសម្បទានទ្រទ្រង់ការធ្វើពិពិធកម្មផលិតផលទេសចរណ៍កម្សាន្តក្នុងព្រៃឱ្យកាន់តែសម្បូរណ៍បែប។ | តំបន់ភ្នំវល្លិ៍ | ក.ស.ក<br>ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | | | | | | | | |
| ៤- | អភិវឌ្ឍប៉ូលទេសចរណ៍សមុទ្រនិងតំបន់ប្រជុំកោះ ជាតំបន់ទេសចរណ៍សមុទ្រកោះប្រណិត | | | | | | | | | | | | | | | | | |
| ៤.១- | ការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍កោះបែបប្រណិត | ១- រៀបចំស្តង់ដាមួយច្បាស់លាស់សម្រាប់សកម្មភាពអាជីវកម្មនិងគម្រោង | ▪ សិក្សា កំណត់ និងអនុវត្តស្តង់ដាមួយច្បាស់លាស់សម្រាប់សកម្មភាពអាជីវកម្មនិងគម្រោងវិនិយោគលើសេវាកម្មទេសចរណ៍សំខាន់ៗ ដូចជាសណ្ឋាគារ ឬរមណីយដ្ឋាននានាក្នុងតំបន់កោះ ដើម្បីធានាគុណភាពនិងការអភិវឌ្ឍប្រកបដោយចីរភាព។ | តំបន់ប្រជុំកោះ | ក.ទ.ច<br>រ.ប.ក | √ | √ | √ | | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | វិនិយោគ លើ សេវាកម្ម ទេសចរណ៍ សំខាន់ៗ | | | | | | | | | | | | | | | | |
| | | ២- លើកកម្ពស់ការថែរក្សានិង អភិរក្សធនធាន តំបន់ឆ្នេរ | ▪ ជំរុញការថែរក្សានិងអភិរក្សតំបន់ឆ្នេរនិងធនធានធម្មជាតិសំខាន់ៗនៅលើកោះដោយមានការកំណត់យន្តការនិងស្ថាប័នទទួលខុសត្រូវច្បាស់លាស់។ | តំបន់ ប្រជុំកោះ | រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៣-ជំរុញការ បង្កើតតំបន់ ប្រជុំកោះនានា ជាឧទ្យាន ជាតិ សមុទ្រ | ▪ កំណត់និងបង្កើតតំបន់ប្រជុំកោះនានាជាឧទ្យានជាតិសមុទ្រ និងដាក់បញ្ចូលជាឧទ្យានបេតិកភណ្ឌអាស៊ាន (ASEAN Heritage Park) ត្រឹមឆ្នាំ ២០៣០។ | តំបន់ ប្រជុំកោះ | ក.ប.ស្ថ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៤-ជំរុញដាក់ បញ្ចូលតំបន់ សក្តានុពល ធនធានធម្មជាតិ នានា ទៅក្នុង UNESCO Biosphere Reserve | ▪ សិក្សានិងបន្តជំរុញដាក់បញ្ចូលទាំងឧទ្យានជាតិកែប តំបន់ក្រុងកែបចាស់ និងឧទ្យានជាតិសមុទ្រខាងលើ និងតំបន់ជីវៈចម្រុះព្រែកចាកទៅក្នុង UNESCO Biosphere Reserve នៅឆ្នាំ២០៣៥។ | តំបន់ ប្រជុំកោះ | ក.ប.ស្ថ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៤.២- | ការកសាង មូលដ្ឋាន អភិវឌ្ឍ សកម្មភាព | ១-កំណត់ការ បែងចែកតំបន់ និងកំណត់ អត្តសញ្ញាណ | ▪ សិក្សាធ្វើការបែងចែកតំបន់ និងកំណត់អត្តសញ្ញាណធនធានធម្មជាតិនិងជីវៈចម្រុះនៅតាមផ្ទៃកនានានៃផ្ទៃសមុទ្រខេត្តកែប ដូចជាតំបន់ដែលសម្បូណ៌ស្មៅសមុទ្រ តំបន់ដែលសម្បូណ៌ផ្កាថ្ម តំបន់ដែល | តំបន់ ប្រជុំកោះ | គ.ជ.អ.ទ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទេសចរណ៍លើផ្ទៃសមុទ្រនិងក្រោមសមុទ្រ | ធនធានធម្មជាតិនិងជីវៈចម្រុះនៅតាមផ្នែកនានានៃផ្ទៃសមុទ្រខេត្តកែប | សម្បូណ៌ត្រីនិងជីវៈចម្រុះសត្វសមុទ្រ ក៏ដូចជាសីតុណ្ហភាពនិងជម្រៅទឹកសមុទ្រតាមតំបន់នីមួយៗ សម្រាប់ជាមូលដ្ឋានក្នុងការអភិរក្សផងនិងរៀបចំបង្កើតផលិតផល ឬសកម្មភាពទសចរណ៍នៅលើផ្ទៃសមុទ្រនិងក្រោមសមុទ្រ។ | | | | | | | | | | | | | | | |
| ៥- | យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍតំបន់ប៉ូលទេសចរណ៍ | | | | | | | | | | | | | | | | | |
| ៥.១- | ពង្រឹងយន្តការគ្រប់គ្រងក្នុងតំបន់ប៉ូលទេសចរណ៍នីមួយៗ | ១-អភិវឌ្ឍនិងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង | ▪ ដោយមានការគាំទ្រពីគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប សហការជាមួយនឹងវិស័យឯកជន ព្រមទាំងសហគមន៍ក្នុងមូលដ្ឋានពាក់ព័ន្ធនឹងវិស័យទេសចរណ៍ដើម្បីធ្វើការរួមគ្នាអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប និងទទួលខុសត្រូវក្នុងការអភិរក្ស ព្រមទាំងរៀបចំផែនការអភិវឌ្ឍគោលដៅទេសចរណ៍និងពង្រឹងប្រសិទ្ធភាពការងារនៅតាមគោលដៅកម្សាន្តក្នុងប៉ូលទេសចរណ៍នីមួយៗ។ | តំបន់ប៉ូលនីមួយៗ | គ.ជ.អ.ទ<br>រ.ប.ក | √ | √ | | | | | | | | | | | |
| | | ២-ពង្រឹងសមត្ថភាព វិស័យឯកជន សមាគម និងសហគមន៍តាមតំបន់ប៉ូលទេសចរណ៍នីមួយៗ | ▪ រៀបចំនិងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពវិស័យឯកជន សមាគម និងសហគមន៍តាមតំបន់ប៉ូលទេសចរណ៍នីមួយៗ ក្នុងការធានាប្រសិទ្ធភាពនិងនិរន្តរភាពក្នុងការគ្រប់គ្រងគោលដៅទេសចរណ៍នីមួយៗ។ | តំបន់ប៉ូលនីមួយៗ | គ.ជ.អ.ទ<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៣-បំពាក់ប្រព័ន្ធបច្ចេកវិទ្យាតាមតំបន់ប៉ូល | ▪ ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសម្រាប់ប៉ូលទេសចរណ៍នីមួយៗ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងការតភ្ជាប់ជាមួយភាគីពាក់ព័ន្ធ | តំបន់ប៉ូលនីមួយៗ | ក.ប.ទ<br>រ.ប.ក | √ | √ | √ | √ | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទេសចរណ៍នីមួយៗ | ជាអាទិ៍ គ្រប់គ្រងស្ថិតិភ្ញៀវទេសចរ កសាងមូលទិន្នន័យ (Data Base) វិស័យទេសចរណ៍ ការផ្សព្វផ្សាយផលិតផលទេសចរណ៍ និងសមាហរណ-កម្មរាល់ទិន្នន័យទេសចរណ៍ទៅក្នុងមជ្ឈមណ្ឌលទិន្នន័យជាតិ (National Data Center) តម្រង់ប្រែក្លាយប៉ូលទេសចរណ៍ទៅជាទេសចរណ៍ឆ្លាតវៃ។ | | | | | | | | | | | | | | | |
| | | ៤-រៀបចំយន្តការផ្សព្វផ្សាយ និងប្រឹក្សាយោបល់ | ▪ រៀបចំយន្តការការផ្សព្វផ្សាយ និងប្រឹក្សាយោបល់ឱ្យបានទូលំទូលាយ សំដៅគាំទ្រដល់ការលូតលាស់នៃវិស័យឯកជន សហគមន៍ទេសចរណ៍ សមាគមទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍ជាតិ និងអន្តរជាតិ។ | តំបន់ប៉ូលនីមួយៗ | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | | | | | | | | | |
| ៦- | **ការអភិវឌ្ឍផលិតផល និងព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗក្នុងខេត្តកែប** | | | | | | | | | | | | | | | | | |
| ៦.១- | ជំរុញការធ្វើពិពិធកម្មគោលដៅទេសចរណ៍ខេត្តកែប | ១- រៀបចំបង្កើតព្រឹត្តិការណ៍ទេសចរណ៍ប្រចាំឆ្នាំថ្មីៗ | ▪ សិក្សា រៀបចំបង្កើតព្រឹត្តិការណ៍ទេសចរណ៍ប្រចាំឆ្នាំថ្មីៗដូចជាៈពិធីបុណ្យក្ដាមសមុទ្រ ពិធីបុណ្យត្រូវតន្ត្រី ពិធីបុណ្យពន្លឺប្រចាំឆ្នាំ វិថីម្ហូបអាហារខេត្តកែប និងការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាទេសចរណ៍លើទឹកប្រចាំឆ្នាំ ជដើម។ | ខេត្តកែប | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ២- អភិវឌ្ឍនិងពង្រឹងរបៀងទេសចរណ៍អាហារសមុទ្រខេត្តកែប | ▪ អភិវឌ្ឍនិងពង្រឹងរបៀងទេសចរណ៍អាហារសមុទ្រខេត្តកែប តាមរយៈការបន្តពង្រឹងគុណភាពម្ហូបអាហារនៅតាមភោជនីយដ្ឋាន និងការផ្គត់ផ្គង់ផលិតផលម្ហូបអាហារនានា។ | ខេត្តកែប | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ៣-សិក្សានិងកំណត់ទីតាំងមួយចំនួននៅ | ▪ សិក្សានិងកំណត់ទីតាំងមួយចំនួននៅក្នុងក្រុងកែបសម្រាប់បង្កើតជាផ្សាររាត្រីដែលមានតាំងលក់ផលិតផលចម្រុះក្នុងស្រុក និងជាពិសេសមុខម្ហូប | តំបន់ប៉ូលនីមួយៗ | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក្នុងក្រុងកែប សម្រាប់បង្កើតជាផ្សាររាត្រី | និងអាហារសមុទ្រធម្មជាតិដ៏សម្បូរបែប សំដៅបង្កើនសកម្មភាពកម្សាន្តនាពេលយប់ផង ជាពិសេសពង្រឹងអត្តសញ្ញាណផលិតផលម្ហូបអាហារខេត្តកែប។ | | | | | | | | | | | | | | | |
| | | ៤-រៀបចំយុទ្ធនាការ "ខ្ញុំស្រលាញ់ខេត្តកែប" | ▪ ជំរុញការបំផុសចលនាមកកម្សាន្តខេត្តកែប តាមរយៈយុទ្ធនាការ "ខ្ញុំស្រលាញ់ខេត្តកែប" និង/ឬ អាចបង្កើតពិធីបុណ្យជាផ្លូវការហៅថាបុណ្យ" ខ្ញុំស្រលាញ់ខេត្តកែប: I LOVE KEP DAY" ដើម្បីគាំទ្រដល់ការផ្សព្វផ្សាយនិងបង្កើនទំហំទីផ្សារទេសចរណ៍មកកាន់ខេត្តកែប។ | ខេត្តកែប | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៧- | ការអភិវឌ្ឍខេត្តកែប-កំពតជាគោលដៅទេសចរណ៍រួម | | | | | | | | | | | | | | | | | |
| ៧.១- | អភិវឌ្ឍគោលដៅកម្សាន្តតំបន់ព្រៃកោងកាងព្រែកអង្កោលនិងព្រែកចាករួមគ្នា | ១-អភិវឌ្ឍគោលដៅកម្សាន្តតំបន់ព្រៃកោងកាងព្រែកអង្កោលនិងព្រែកចាករួមគ្នា | ▪ តាមរយៈការជំរុញនិងពន្លឿនការរៀបចំ និងដាក់អនុម័តឱ្យប្រើប្រាស់ផែនការប្រើប្រាស់ដីតំបន់ព្រៃកោងកាងអង្កោលនិងព្រែកចាក ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការមេគ្រប់គ្រងនិងអភិរក្សសម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យអេកូទេសចរណ៍ក្នុងតំបន់។ | តំបន់អង្កោល | គ.អ.ធ.ក<br>រ.ប.ក<br>រ.ប.កព | √ | √ | √ | √ | | | | | | | | | |
| | | ២-ពង្រឹងសហគមន៍អេកូទេសចរណ៍តំបន់ព្រៃកោងកាងអង្កោល-ព្រែកចាក | ▪ ពង្រឹងសហគមន៍អេកូទេសចរណ៍តំបន់ព្រៃកោងកាងអង្កោល-ព្រែកចាក ក្នុងការការចូលរួមថែរក្សាព្រៃកោងកាងនិងអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ដើម្បីទាញយកផលប្រយោជន៍ពីទេសចរណ៍ក្នុងតំបន់នេះ។ | តំបន់អង្កោល | ក.ទ.ច<br>រ.ប.ក<br>រ.ប.កព | √ | √ | | | | | | | | | | | |
| | | ៣-ពង្រឹងការអភិវឌ្ឍនិង | ▪ តាមរយៈការរៀបចំនូវព្រឹត្តិការណ៍ទេសចរណ៍ ព្រឹត្តិការណ៍កីឡា ព្រឹត្តិការណ៍វិនិយោគ និងពិធី | ខេត្តកែប<br>ខេត្តកំពត | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្សព្វផ្សាយទេសចរណ៍រួមគ្នា | បុណ្យរួមគ្នា ដូចជាពិធីបុណ្យព្រៃកោងកាង និងពិធីបុណ្យម្រេច ជាដើម។ | | រ.ប.កព | | | | | | | | | | | | | |
| | | ៤-បង្កើតខ្សែបណ្តាញដឹកជញ្ជូនសាធារណៈរួមគ្នា | ▪ សិក្សានិងពិនិត្យលទ្ធភាពបង្កើតរថយន្តក្រុង ខ្សែរថភ្លើង (Tramways) និងទូកទេសចរណ៍តភ្ជាប់រវាងខេត្តកែបនិងកំពត ដើម្បីសម្រួលនិងកាត់បន្ថយចំណាយនៃការធ្វើដំណើរដល់ភ្ញៀវទេសចរនិងប្រជាពលរដ្ឋ។ | ខេត្តកែប<br>ខេត្តកំពត | ក.ទ.ច<br>រ.ប.ក | √ | √ | √ | | | | | | | | | | |
| II | យុទ្ធសាស្ត្រលើកកម្ពស់វិនិយោគ អភិវឌ្ឍធនធានមនុស្ស និងផ្សព្វផ្សាយទីផ្សារ | | | | | | | | | | | | | | | | | |
| ១- | ការលើកកម្ពស់វិនិយោគនិងអភិវឌ្ឍធនធានមនុស្ស | | | | | | | | | | | | | | | | | |
| ១.១- | ការលើកកម្ពស់វិនិ-យោគទេសចរណ៍ | ១-កំណត់ទីតាំងដែលមានសក្តានុពលសម្រាប់ការវិនិយោគទេសចរណ៍ | ▪ ធ្វើការសិក្សានិងកំណត់ទីតាំងដែលមានសក្តានុពលពិសេសនៅតាមបណ្តាទីតាំងរបស់រដ្ឋ ដើម្បីត្រៀមសហការជាមួយវិស័យឯកជន ក្នុងការអនុវត្តគោលដៅទាំងនោះ។ | ខេត្តកែប | ក.ទ.ច<br>រ.ប.ក | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| | | ២-រៀបចំជាវេទិកាវិនិយោគទេសចរណ៍ខេត្តកែបប្រចាំឆ្នាំ | ▪ រៀបចំវេទិកាវិនិយោគទេសចរណ៍ខេត្តកែបប្រចាំឆ្នាំ ដើម្បីជំរុញនិងទាក់ទាញការវិនិយោគពីវិនិយោគិននៅក្នុងស្រុក និងការវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងផ្សព្វផ្សាយរវាងវិនិយោគិននិងសហគ្រិន។ | | | | | | | | | | | | | | | |
| | | ៣- បង្កើតភូមិគ្រឹះឆ្នេរសមុទ្រកែប | ▪ សិក្សានិងកំណត់ទីតាំងសមស្រប ដើម្បីរៀបចំបង្កើតជាភូមិគ្រឹះឆ្នេរសមុទ្រកែប ក្នុងគោលបំណងបង្កើតសារមន្ទីរសមុទ្រ ដែលនឹងក្លាយជាមណ្ឌលរក្សាឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រសម្រាប់ទទួលភ្ញៀវទេសចរ និងអ្នកសិក្សាស្រាវជ្រាវមកពីគ្រប់មជ្ឈដ្ឋាន ពិសេសវិនិយោគិនដែលមាន | តំបន់អង្កោល | ក.ទ.ច<br>ក.ប.ស្ថ<br>គ.អ.ធ.ក<br>រ.ប.ក | √ | √ | √ | √ | √ | | | | | | | | |

